# បត្តានុមោទនាមយៈ

## *បុណ្យកើតអំពីការអនុមោទនា*

## ភាគទី ៧




*រៀបរៀងដោយ*

*ខ្ញុំព្រះករុណាអាត្មាភាព* **ភិក្ខុសីលប្បញ្ញោ ផៃ សុផល្លី**

**វត្តនិគ្រោធវ័ន គល់ទទឹង**

ព.ស.២៥៥៧

ឈ្មោះសៀវភៅ **បត្តានុមោទនាមយៈ**
រៀបរៀងដោយ **ភិក្ខុសីលប្បញ្ញោ ផៃ សុផល្វី**
ចេញផ្សាយ   លើកទី ១
កាលបរិច្ឆេទ  ព.ស. ២៥៥៧
ទីកន្លែងធ្វើ    វត្តនិគ្រោធវ័នគល់ទទឹងភូមិកោះក្របី
សង្កាត់ព្រែកថ្មី ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ

# អារម្ភកថា

បុណ្យបានមកដោយសារជ្រះថ្លា ពេញចិត្តត្រេកអរទទួល អនុមោទនាចំណែកបុណ្យជាមួយគេ ឬដែលគេបានឱ្យ ។ ការជ្រះថ្លាពេញចិត្ត ត្រេកអរនូវចំណែកបុណ្យនេះ ទោះជាគេមិនបានឱ្យក៏ដោយ គ្រាន់តែយើងលួចជ្រះថ្លា ត្រេកអរក្នុងចិត្តតាមគេ ឬសុំចែកពីគេក៏ដោយ ក៏បានបុណ្យអានិសង្សដូចគ្នាដែរ ព្រោះការលួចបុណ្យគេនេះមិនបាបទេ ឯការសុំបុណ្យពីគេទៀតសោត ក៏មិនមែនជារឿងថោកទាបអ្វីដែរ តែបើគេជ្រះថ្លាបានជូនបុណ្យនោះៗ ដល់យើងដោយផ្ទាល់វិញនោះ យើងគ្រាន់តែលើកដៃសំពះ ហើយអនុមោទនាទទួលយកដោយពោល សាធុ ! សាធុ ! សាធុ ! បីដង ដោយចិត្តត្រេកអរ រីករាយប៉ុនហ្នឹង គឺបានបុណ្យផលានិសង្ស ហាក់ដូចជាយើងបានធ្វើដោយផ្ទាល់អ៊ីចឹងដែរ ។ មានអ្នកខ្លះដោយមិនបានយល់ឱ្យច្បាស់ពីរឿងនេះ ពេលគេជូនកុសលផលបុណ្យ ហាក់ដូចជាមិនសប្បាយចិត្ត គិតខឹងនឹងអ្នកជូននោះថា ម៉េចចាំបាច់ជូនដល់គេ? ធ្វើមើលតែហ្នឹង ខ្វះលទ្ធភាព មិនអាចធ្វើបុណ្យដោយខ្លួនឯងបានឬ ? ត្រឹមតែលើកដៃសំពះ ហើយពោលថា **សាធុ** ដោយចិត្តរីករាយប៉ុនហ្នឹង វាគ្មានអ្វីខាតបង់ ឬពិបាកធ្វើនោះឡើយ ។

មានអ្នកខ្លះទៀត ពេលគេជូនបុណ្យមក ធ្វើព្រងើយ ឬធ្វើហីមិនដឹង មិនទាំងចេះទទួលអនុមោទនាបុណ្យកុសល ដែលគេខំជូនហ្នឹងផង ។

ការអនុមោទនាទទួលយកបុណ្យកុសលនេះ គឺសំខាន់ខ្លាំងណាស់ ពិសេសសម្រាប់ពពួកប្រេត នរក អសុរកាយ បើមិនចេះអនុមោទនា ទទួលយកកុសលផលបុណ្យហ្នឹងទេ គឺមិនអាចរួចផុតពីកំណើតថោកទាប ទុក្ខទោសវេទនាទាំងអស់នោះ ហើយបានទៅកើតក្នុងស្ថានសុគតិភពសួគ៌ទេវលោកបានឡើយ ។ ម៉្លោះហើយបានជាពេលកំពុងរស់នៅ ត្រូវចេះទទួលអនុមោទនាបុណ្យកុសលឱ្យហើយ ក្រែងលោដំណើរមិនទៀង ផ្សៀងគតិ ភ្ញាត់ធ្លាក់ទៅកើតក្នុងកំណើតថោកទាប មិនល្អ មានកំណើត ប្រេត នរកជាដើមនោះ ពេលកូនចៅញាតិមិត្ត ធ្វើបុណ្យឧទ្ទិសជូនទៅ ចេះអនុមោទនាទទួលយក នាំឱ្យបានរួចផុតពីកំណើតទុក្ខទោសទាំងអស់ហ្នឹង បានទៅកើតក្នុងសុគតិភពវិញ តែបើកាលនៅជាមនុស្ស មិនទាំងចេះអនុមោទនាបុណ្យផង ចុះដល់ពេលស្លាប់ទៅ កូនចៅ ញាតិមិត្រ ឧទ្ទិសបុណ្យជូនទៅ ធ្វើម៉េចអាចទទួលយកនូវបុណ្យនូវកុសលផលបុណ្យនោះបានទៅ ?

សៀវភៅ **បត្តានុមោទនាមយៈនេះ** ខ្ញុំសង្ឃឹមថា នឹងបានជាផ្លូវចង្អុលបង្ហាញអំពីអានិសង្សខ្លះៗ នៃការធ្វើបុណ្យរបស់ពុទ្ធបរិស័ទទាំងឡាយ ដែលជាអ្នកប្រាថ្នានូវបុណ្យ ប្រាថ្នានូវសេចក្ដីសុខនោះ ។

**សូមអនុមោទនា** !!!

ថ្ងៃ ៧ រោច ឆ្នាំម្សាញ់ បញ្ចស័ក ព.ស. ២៥៥៧

**ភិក្ខុសីលប្បញ្ញោ ឆៃ សុផល្លី**

# បញ្ជីមាតិកា


**បុណ្យកើតអំពីការអនុមោទនា** .... ... ... ... ... .........១

ចំណែកបុណ្យដែលគេឧទ្ទិសឱ្យ ២ ប្រការ..... ..... .... ..... ..... .... ៣

វិធីចែកបុណ្យប្រភេទអនុទ្ទិស្សិកបត្តិ... ... ... ... ... ... .. . ៦

រឿងឧបាសកម្នាក់... ... ... ... ... ... ....... ..... ........ ..... ៧

រឿងសង្ខព្រាហ្មណ៍ ... .... ... .... ... ... ...... ..... .... ..... ៨

រឿងប្រេតជាមាតានៃព្រះសារីបុត្រ.. ... ........ . ..... ...... ..... ១០

បុណ្យទក្ខិណានុបទ្បាន ... ... ... ... ... ... ... ... ... . ...១៦

វិហារវិមាន... ... ... .... .... ... .... .... ........ ..... .... .. ....... ... ១៩

ទ្វារបាលវិមាន.... .... ... .. ... .... ..... ........... ....... .. ២៦

ស្វាមីរបស់ធិតានៃកិដុម្ពីក៏មានកាយក្រអូបមាត់ក្រអូប .. ២៩

ការអនុមោទនាបុណ្យជាការប្រដៅចិត្តមួយផ្នែក .. ... ៣១

***សិក្សាគោលផ្សេងៗ*** ... ... ... ... ... ..... ... ... ... ... ៣៤

សេចក្តីសុខរបស់មាតាបិតានិងកូនប្រុសស្រី ... ... ... .. ... ៣៤

ម្ងប់ ៥ យ៉ាង ... ... ... ... ... ... ... ... ... ... ... ... .. ...៣៥

សង្វេគវត្ថុ ៨ ប្រការ ..... ... .... ... ...... ... ... .... ... ៣៥

លក្ខណៈវិវាហ ៨ យ៉ាង ... ......... ... . ... ... ... ... ៣៧

វត្ថុដែលមិនដឹងថាឆ្អែត ១៦ យ៉ាង.. . ... ... ... ... ... ៣៥

ជីវិតមានឧបមា ៧ យ៉ាង ... ... ... ..... ... ... ... .... ៣៩

អំណាចរបស់មច្ចុរាជ ១៧ យ៉ាង... ... .. ... .. ... ... ៤៣

បុគ្គលដែលមិនខ្លាចស្លាប់ ...... ... ... . .. ... ... ... ... ៤៦

សទ្ធាធ្វើឲ្យកើតគុណ ១២ ប្រការ... .... ... ... ... ... ... ៤៦

អានិសង្សសទ្ធា ៥ យ៉ាង ..... ... ... ...... ... ... ... ... ៤៧

គុណរបស់សីល ... ... ... ... ... ... .... ... ... ... ... . ៤៧

អាវុធដ៏ឆ្នើមបំផុត ... ... ... ... ... . ... ... ... ... .. ... ៥១

អានិសង្សកតញ្ញូកតវេទី ... .. ... ... ... ... ... ... .. ... ៥២

អានិសង្សរបស់បុគ្គលប្រព្រឹត្តធម៌ ........ ... .. ... ... ៥៣

ផ្លូវមកនៃសំណាង ៦ យ៉ាង ... .. . .... ... ... ... ... ... ៥៤

ផ្លូវមកនៃប្រយោជន៍ ... ... ... ... .. .. ... ... .. ... ... . . ៥៥

បុគ្គលដែលរលឹកជាតិបាន ៦ ជំពូក ... .. ... ...... ... ៥៥

បុគ្គលដែលមិនបានជួបព្រះសិអារ្យមេត្រី ៦ ជំពូក... ... ៥៦

សម្បត្តិរកបានដោយកម្រ ៦ យ៉ាង ... ... .. . ... ... ... ៥៦

កំណាប់ទ្រព្យ ៤ យ៉ាង ... ... .... ... ... ... ... ... ... ... ៥៧

វុឌ្ឍិធម៌ គឺធម៌ជាគ្រឿងចំរើន ៥ យ៉ាង ... ... .. ... ... ... ៥៧

ចូរពិចារណាអត្តភាពឲ្យមានលក្ខណៈ ៤ យ៉ាង .. ... ៥៧

ជីវិត គឺអត្តភាពមានលក្ខណៈ ៤ យ៉ាង ... ... ... ... ... ៥៨

ពុទ្ធភាសិត ៤ ខ ... ..... ... ... ... ... ... .. ... ... ... .. ៥៨

សេចក្តីគ្រាំគ្រា ៤ យ៉ាង ... ... .. ...... .... ... ... ... ... ៥៩

ផ្លូវនៃសេចក្តីស្លាប់ និងមិនស្លាប់. ... ... . ... ... ... ... ៥៩

វត្ថុដែលជាកំពូលនៃវត្ថុទាំងឡាយ ៤ យ៉ាង . ... ... ... ៥៩

សុខ ៤ យ៉ាង ... ... ... ... .... ... ... ... . ... ... ... ... ៦០

សត្វដែលមិនគួរសម្រេចធម៌មាន ១៥ ប្រការ..... ... ... ៦០

អនុត្តរិយធម៌ ៦ យ៉ាង ... ... ... ... ... ... .. ... ... ...... ៦១

វត្ថុដែលប្រព្រឹត្តទៅមិនបាន ១៦ យ៉ាង ... ... ... .. ... ៦២

អត្ថនៃពាក្យថា មនុស្ស ៣ យ៉ាង ... ..... ... ... ... ... ៦៣
ទ្រព្យសម្បត្តិដែលបានមកត្រូវប្រើដោយឋាន ៥ យ៉ាង.. ៦៣
ធម្មទ្វេស ៤ យ៉ាង ... ... ... ... . ... ... ... ... ... ... ... ៦៤
ជីវិតមានឧបមាដោយធម៌ ៣ ... ... ... .... ... ... ... ៦៤
ធម្មជាតិ ៣ យ៉ាង ... ... ... ... .. ... .. ... ... ... ... ... ៦៥
អច្ឆេន្ទិធម៌ ... ... ... . ... ... ... ... ..... ... ... ... .. ... ៦៥
អគារិយធម៌ ... ... ... ... ...... ... ..... ... ... ... ... ... ៦៦
ហេតុអស្ចារ្យមហាសមុទ្រ ៨ យ៉ាង ... ........ ... ... ... ៦៦
ធម៌គួរឲ្យសង្វេគខ្លាច មិនប្រមាទ ... ... .. .... ... ... ... ៦៨
សប្បុរសប្រៀនដោយធម៌ ៥ យ៉ាង ... ... ..... ... ... ... ៧២
ពិចារណាសេចក្ដីស្លាប់មិនមាននិមិត្ត ៥ យ៉ាង . ... ... ៧២
សមយសូត្រ ... ... .. ... ... ... ... ... ... ..... ... ... ... ៧២
មាតុបោសកសូត្រ . ... .. ... ... ... ... ...... ... .. ... ... ៧៣
មានត្ថទ្ធសូត្រ ... ... ... . ... ... ... ... .... ... ... ... ... ៧៣
តតិយទេវសូត្រ ... ... ... . ... ... ... ... .... ... ... ... ... ៧៤
សេរីសូត្រ ... ... ... ... ... .. ... ... ... ... ... ... ... ... . ៧៤
បឋមអប្បមាទសូត្រ ... ... .. ... ..... ... . ... ... ... ... ៧៥
ឋានសូត្រ ... .... ... ... ... ... .. ... ... ... ... ... ... ... ៧៥
អយ្យិកាសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... .. ៧៦
គម្ពីរជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះ .. . ... ៧៧



## ការទទួលបុណ្យ

*កូនជាទីស្រឡាញ់* !!!

*កូនត្រូវសិក្សានូវចំណុចនៃការទទួលបុណ្យទាំង ៤ នេះគឺៈ*

*១-អនុមោទនាត្រេកអរជ្រះថ្លានឹងកុសលគឺជាបុណ្យ ។*

*២-បុណ្យដែលទទួលបាន អាចលាងជម្រះបាបក្នុងចិត្តបាន ។*

*៣-មានបុណ្យចូលទៅនៅក្នុងចិត្ត ប្រសើរជាងទេវតាសណ្ឋិតក្នុងខ្លួន ។*

*៤-អនុមោទនាទទួលបុណ្យបាន ព្រោះមិនមានមានះ និងការស្អប់ខ្ពើម ។*

# នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។
# សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ អង្គនោះ។

## បត្តានុមោទនាមយៈ

## *បុណ្យកើតអំពីការអនុមោទនា*

*នៅក្នុងអដ្ឋកថា បរមត្ថទីបនីថាៈ បុញ្ញកិរិយាវត្ថុ គឺការអនុមោទនា(បុណ្យ) គប្បីជ្រាបដោយអំណាចនៃការអនុមោទនាចំណែកបុណ្យ ដែលអ្នកដទៃឱ្យហើយ ឬបុណ្យដែលអ្នកដទៃធ្វើហើយទាំងអស់ថា* ***សាធុ*** *(ល្អហើយ) ។*

*គម្ពីរបរមត្ថជោតិកថាៈ* ***បត្តានុមោទនា*** *សម្តែងវចនត្ថៈថា* ***បត្តិយា អនុមោទនំ ⇨ បត្តានុមោទនំ*** *ការឃើញល្អធ្វើតាម ឬទទួលត្រេកអរតាម ដោយសេចក្តីពេញចិត្តនូវចំណែកបុណ្យដែលគេឧទ្ទិសមកឱ្យឈ្មោះថា* ***បត្តានុមោទនៈ*** *បានដល់ ការត្រេកអរទទួលចំណែកបុណ្យ ដែលគេឧទ្ទិសមកឱ្យ ។*

*ពាក្យថា* ***បត្តិ*** *ក្នុងបត្តិទាននោះ ជាទាន សីល ភាវនាដែលខ្លួនព្យាយាមកសាងឱ្យកើតឡើងហើយ ឧទ្ទិសឱ្យដល់បុគ្គលដទៃ ចំណែកពាក្យថា* ***បត្តិ*** *នៅក្នុងបត្តានុមោទនានោះ បានដល់កុសលដែលគេឧទ្ទិសឱ្យនោះ បានមកដល់ខ្លួនហើយ ដោយផ្លូវវាចា និងអក្សរដូច្នោះ ទើបសម្តែងវចនត្ថៈ ។*

ន័យម្យ៉ាងទៀតថា **បាបិយតីតិ បត្តិ** កុសលដែលអ្នកដទៃគប្បីឧទ្ទិសឱ្យ ដូច្នោះ ឈ្មោះថា **បត្តិ, បត្តឹ អនុមោទន្តិ សាធុការំ ទទន្តិ ឯតេនាតិ បត្តានុមោទនំ** ជនទាំងឡាយ រមែងត្រេកអរនូវបុណ្យកុសល ដែលគេឧទ្ទិសមកឱ្យដោយការបញ្ចេញវាចាថា **សាធុ** ដោយចេតនានោះ ដូច្នោះ ចេតនានោះ ឈ្មោះថា **បត្តានុមោទនៈ** បានដល់មហាកុសលចេតនា ដែលទាក់ទងជាមួយការអនុមោទនា ។

កាលពិចារណា មើលតាមគោលវចនត្ថៈដែលសម្តែងហើយនេះ ក៏គប្បីឃើញបានថា ចេតនានៅក្នុងមហាកុសលសោមនស្សដួងណាមួយនោះពិតៗ ជាបត្តានុមោទនាកុសលយ៉ាងបរិបូរណ៌ ចំណែកចេតនានៅក្នុងមហាកុសលឧបេក្ខា ដួងណាមួយនោះ ជាបត្តានុមោទនាកុសលមិនបរិបូរណ៌ ព្រោះចិត្តក្នុងខណៈនោះ ខ្វះបីតិសោមនស្សចំពោះបុណ្យកុសលដែលគេឧទ្ទិសមកឱ្យត្រឹមតែធ្វើឱ្យថ្លៃងវាចាថា **សាធុ សាធុ** (ល្អហើយៗ) តាមភាសារបស់ខ្លួនប៉ុណ្ណោះ ដូច្នោះការអនុមោទនា ដែលជាបត្តានុមោទនាកុសល យ៉ាងបរិបូរណ៌ត្រូវមានចិត្តប្រកបដោយបីតិសោមនស្ស បើក្រៃលែងជាញាណសម្បយុត្តសោមនស្សផងហើយ ក៏ជាបត្តានុនោទនាកុសលយ៉ាងល្អក្រៃលែង ។ ការអនុមោទនាបុណ្យដែលមិនឈ្មោះថា បត្តានុមោទនាដោយត្រង់

ការអនុមោទនាចំណែកបុណ្យ ដែលមិនឈ្មោះថា បត្តានុមោទនា ដោយត្រង់នោះ គឺកាលបានឃើញគេកំពុងធ្វើបុណ្យ គឺការបរិច្ចាគទាន រក្សាសីល ចម្រើនភាវនា ឬបានឃើញពាក្យចារិកឈ្មោះម្ចាស់របស់ដែលជាប់នៅក្នុងវត្ថុ ដែលកសាងថ្វាយ(សង្ឃជាដើម)ក៏កើតបីតិសោមនស្សផង ដោយហេតុដែលគេមិនបានពោលប្រាប់ ឬឧទ្ទិសចំណែកបុណ្យនោះឱ្យទេ ការដែលបីតិ-សោមនស្ស ចំពោះការងារដែលល្អរបស់បុគ្គលដទៃយ៉ាងនេះ នោះនឹងបញ្ចេញវាចាថា សាធុៗ ឬថា ល្អណាស់ក៏ដោយ ឬមិនបានបញ្ចេញវាចាក៏ដោយ មិនបានឈ្មោះថា បត្តានុមោទនា ដោយត្រង់ត្រឹមតែជាអនុលោមប៉ុណ្ណោះ, សម្រាប់ការអនុមោទនាចំណែកបុណ្យដែលបានឈ្មោះថា ជាបត្តានុមោទនាកុសលពិតនោះ បានដល់ បុណ្យកុសលដែលអ្នកធ្វើបានព្យាយាមកសាងឡើង ហើយនាំមកពោលប្រាប់ ឬឧទ្ទិសឱ្យការអនុមោទនាចំណែកបុណ្យដែលម្ចាស់របស់ពោលប្រាប់ ឬឧទ្ទិសឱ្យដូច្នេះទើបបានឈ្មោះថា បត្តានុមោទនាកុសលដោយត្រង់ ។

## ចំណែកបុណ្យដែលគេឧទ្ទិសឱ្យ ២ ប្រការ

១- **ឧទ្ទិស្សិកាបត្តិ** ចំណែកបុណ្យដែលគេឧទ្ទិសឱ្យដោយចំពោះ

២- **អនុទ្ទិស្សិកាបត្តិ** ចំណែកបុណ្យដែលគេឧទ្ទិសឱ្យមិនចំពោះការបែកបទតាមបាលីវេយ្យាករណ៍ដូច្នេះ ។

**ឧទ្ទិស្ស ⇨ ឥក ⇨ បត្តិ⇨ ឧទ្ទិស្សិកបត្តិ**

**ឧទ្ទិស្ស⇨** *ការចំពោះ*, **ឥក⇨** *មាន*, **បត្តិ ⇨** *កុសលដែលគេផ្សាយឱ្យ កាលរួមបទទាំង ៣ នេះចូលគ្នាហើយ ក៏ប្រែថា កុសលដែលគេផ្សាយ ឱ្យដោយមានការចំពោះ ។*

**ន ⇨ ឧទ្ទិស្ស ⇨ ឥក ⇨ បត្តិ⇨ អនុទ្ទិស្សិកបត្តិ**

**ន ⇨** *មិន*, **ឧទ្ទិស្ស⇨** *ការចំពោះ*, **ឥក ⇨** *មាន*, **បត្តិ⇨** *កុសលដែលគេផ្សាយឱ្យ កាលរួមបទទាំង ៤ នេះចូលគ្នាហើយ ក៏ប្រែថា កុសលដែលគេផ្សាយឱ្យដោយមិនមានការចំពោះ ។*

*ការបែងចែកបុណ្យកុសលទាំង ២ ប្រការនេះ អ្នកដែលបានទទួលចំណែកបុណ្យប្រភេទដែលជាឧទ្ទិស្សិកបត្តិ កាលបានបញ្ចេញវាចាថា សាធុ...! ហើយក៏បានទទួលផលមួយរំពេចដូចជាពួកប្រេតដែលជាញាតិរបស់ព្រះបាទពិម្ពិសារ តាំងតែអំពី ៩២ កប្បមុន កាលព្រះបាទពិម្ពិសារ បានកសាងនូវវត្តវេឡុវ័នារាម ថ្វាយចំពោះព្រះសម្មាសម្ពុទ្ធ ព្រះមហាក្សត្រមិនបានបែងចែកចំណែកបុណ្យ ដោយចំពោះឲ្យដល់ពួកប្រេតទាំងនោះឡើយ ត្រឹមតែទ្រង់ផ្សាយទៅដោយមិនចំពោះប៉ុណ្ណោះ ដូច្នោះពួកប្រេតទាំងនោះ ទើបបាននាំគ្នាបញ្ចេញសម្លេងស្រែកយំ សុំចំពោះព្រះមហាក្សត្រ លុះព្រឹកស្អែកឡើងព្រះមហាក្សត្រ ក៏ប្រញាប់ស្តេចទៅគាល់ព្រះសម្មាសម្ពុទ្ធ ក្រាបទូលសួរដល់រឿងដែលបានជួប*

ប្រទះមកនោះ ចំពោះព្រះសម្មាសម្ពុទ្ធ ។ ព្រះអង្គទើបសម្តែងប្រាប់ថា ជាសំឡេងរបស់ប្រេតដែលជាញាតិមក ស្រែកសុំចំណែកបុណ្យ ព្រះអង្គមិនបានឧទ្ទិសចំណែកបុណ្យទាំងពួងដែលទ្រង់បំពេញឱ្យដល់គេដោយចំពោះឡើយ គេទាំងនោះបានតាំងចិត្តរង់ចាំដើម្បីនឹងបានទទួលចំណែកបុណ្យ អំពីព្រះអង្គមកអស់រយៈពេលយូរលង់ហើយ។ ដូច្នោះ ព្រះបាទពិម្ពិសារទើបទ្រង់បានចាត់ការធ្វើបុណ្យឡើងថ្មីទៀតជាគ្រាទី ២ ហើយទ្រង់បានចែកចំណែកបុណ្យនោះ ឱ្យដល់ប្រេតទាំងនោះដោយចំពោះ ចំណែកពួកប្រេតទាំងឡាយ កាលបានទទួលចំណែកបុណ្យពីព្រះបាទពិម្ពិសារ ដែលទ្រង់ចែកឱ្យដោយចំពោះហើយទើបនាំគ្នាបញ្ចេញវាចាថា សាធុ..! ផលបុណ្យក៏ប្រាកដកើតឡើងមួយរំពេច ដោយបានទទួលអាហារមកបរិភោគសម្រាលសេចក្តីស្រេកឃ្លាន ដែលលំបាកមកអស់រយៈពេលជាយូរលង់ ទើបតែបានបរិភោគក្នុងខណៈនោះឯង ។ នេះជាផលដែលបានទទួលដោយប្រាកដជាក់អំពីការបែងចែកចំណែកបុណ្យដោយចំពោះ ។ សម្រាប់អ្នកដែលបានទទួលចំណែកបុណ្យ ប្រភេទជាអនុទ្ទិស្សិកបត្តិនោះ មិនបានទទួលផលប្រាកដជាក់ក្នុងមួយរំពេច ដូចអ្នកដែលបានទទួលចំណែកបុណ្យ ប្រភេទឧទ្ទិស្សិកបត្តិនោះទេ តែទោះជាយ៉ាងណាក៏ដោយ អានិសង្សនៃការអនុមោទនាចំណែក

បុណ្យ ប្រភេទអនុទ្ទិស្សិកបត្តិរបស់ពួកប្រេតទាំងឡាយ ក៏មិនសាបសូន្យទៅឡើយ, ចំពោះការទទួលចំណែកបុណ្យប្រភេទដែលជាអនុទ្ទិស្សិកបត្តិវេលាណា វេលានោះការអនុមោទនាចំណែកបុណ្យប្រភេទដែលជាអនុទ្ទិស្សិកបត្តិនេះ ក៏ចូលរួមជួយឧបត្ថម្ភ ការអនុមោទនាប្រភេទជាឧទ្ទិស្សិកបត្តិ ឱ្យមានកម្លាំងខ្លាំងឡើងក្នុងខណៈនោះ ។ តាមដែលពោលមកហើយនេះ សំដៅដល់អ្នកដែលបានស្លាប់ទៅហើយ ក៏បានទៅកាន់កំណើតដែលជាបរទត្តូបជីវិកប្រេតមួយពួកវិនិបាត អសុរនិងវេមានិក-ប្រេត ដែលជាពួកទេវតាជាន់ទាបក្នុងចាតុម្មហារាជិកាភូមិម្យ៉ាងប៉ុណ្ណោះ សម្រាប់ក្នុងពួកមនុស្សផងគ្នានេះ មានការអនុមោទនាចំណែកបុណ្យប្រភេទដែលជាឧទ្ទិស្សិកបត្តិ ឬ អនុទ្ទិស្សិកបត្តិដូចគ្នា តែផលដែលបានទទួលនោះ មិនមែនជារបស់របរមាស ប្រាក់ អាហារបរិភោគ ទីនៅអាស្រ័យ ដូចគ្នានឹងពួកប្រេតដែលបានទទួលនោះទេ ត្រឹមតែបានទទួលផល គឺមានចិត្តសុខសប្បាយ មិនក្តៅក្រហាយ មុខមាត់ស្រស់បស់មិនស្រអាប់ប៉ុណ្ណោះ និងត្រូវទទួលផលជាសេចក្តីសុខក្នុងបរលោក ឬក្នុងបច្ចុប្បន្នក៏មាន ។

## **វិធីចែកបុណ្យប្រភេទអនុទ្ទិស្សិកបត្តិ**

សម្រាប់វិធីចែកបុណ្យប្រភេទអនុទ្ទិស្សិកបត្តិ មានវិធីចែកដូច្នេះថា ***ឥទំ មេ បុញ្ញំ សព្វសត្តានំ ទេមិ*** សូមឧទ្ទិសការធ្វើបុណ្យ

ដែលទាក់ទងនឹងទាន សីល ភាវនា របស់ខ្ញុំម្ចាស់នេះ ឱ្យដល់សព្វសត្វទាំងពួងទាំងឡាយ ។ ចេតនាជាហេតុអនុមោទនា សូម្បីរបស់ពួកប្រេតទាំងឡាយ រមែងជាគុណជាតិឱ្យផលក្នុងខណៈនោះបាន, មិនបាច់ពោលថ្វីដល់ចេតនា ដែលជាហេតុអនុមោទនារបស់មនុស្សឡើយ ។ ក្នុងសេចក្តីនេះ មានរឿងទាំងនេះ (ជាឧទាហរណ៍)។

## រឿងឧបាសកម្នាក់

បានឮមកថា ក្នុងកាលនៃព្រះពុទ្ធព្រះនាមកស្សបៈ មានឧបាសកម្នាក់ ជាសោតាបន្ន បានចុះទូកជាមួយនឹងកុដុម្ពីក៏ជាងកាត់សក់ម្នាក់ ។ ក្នុងថ្ងៃទី ៧ នាវាក៏បានគៀងនៅត្រង់កណ្តាលនៃសមុទ្រ ។ ជនទាំងពីរនាក់នោះឯង ដេកលើបន្ទះក្តារមួយហើយ ក៏ទៅដល់កោះមួយ បណ្តាជនទាំងពីរនាក់នោះ ជាងកាត់សក់សម្លាប់សត្វទាំងឡាយហើយ អាំងស៊ីបានឱ្យដល់ឧបាសកខ្លះ ឧបាសកពោលថា ខ្ញុំគ្រប់គ្រាន់ហើយ ដូច្នោះ មិនបរិភោគហើយ គិតថា ក្នុងទីនេះក្រៅពីត្រៃសរណៈចេញហើយ ទីពឹងដទៃរបស់អាត្មាអញមិនមានឡើយ ។ កាលបើឧបាសកនោះរលឹកនូវគុណនៃព្រះរតនត្រ័យយ៉ាងនេះ, ស្តេចនាគរាជក៏កើតឡើងហើយក្នុងកោះនោះនិម្មិតសរីរៈរបស់ខ្លួនធ្វើជាទូកយ៉ាងធំពេញដោយរតនៈ ៧ ប្រការ ។ សមុទ្រទេវតា បានជាអ្នកកាច់ចង្កូតទូក ឋិតនៅលើ

ទូកស្រែកប្រកាសថា បុគ្គលអ្នកទៅកាន់ជម្ពូទ្វីបមានដែរឬទេ ? ឧបាសកប្រាប់ថាយើងទាំងឡាយនឹងទៅកាលបើទេវតាពោលថា ចូរអ្នកឡើងទូកចុះ ដូច្នេះ កំពុងតែឡើងទូកបានហៅជាងកាត់សក់ឲ្យឡើងទូកផង ។ ទេវតាពោលថា បុគ្គលនោះមិនមានគុណនិងមារយាទឡើយ ព្រោះហេតុនោះ បុគ្គលនោះជាអ្នកមិនគួរដើម្បីនឹងចុះទូកនេះទេ ។ ឧបាសកពោលថា ហេតុនោះ ចូរស្ងៀសសិនចុះ ខ្ញុំនឹងឲ្យនូវចំណែកបុណ្យអំពីទាន ដែលខ្ញុំបានឲ្យហើយ ពីសីលដែលខ្ញុំបានរក្សាហើយ និងអំពីភាវនាដែលខ្លួនខ្ញុំអប់រំហើយដល់បុរសនុ៎ះ, ជាងកាត់សក់ពោលថា ខ្ញុំសូមអនុមោទនា ។ ក្នុងពេលនោះ ទេវតាឱ្យបុរសនោះឋិតនៅលើទូក ហើយបានអុំទូកនោះសំដៅទៅទីក្រុងពារាណសី ញុំាងទ្រព្យឱ្យតាំងនៅក្នុងផ្ទះនៃជនទាំងពីរនាក់នោះស្រេចហើយ ក៏បានត្រឡប់ទៅកាន់វិមានរបស់ខ្លួនវិញ ។

(អដ្ឋកថាសីលានិសង្សជាតក ក្នុងចតុក្កវគ្គ ទុកនិបាត)

## រឿងសង្ខព្រាហ្មណ៍

ក្នុងអតីតកាល ទីក្រុងពារាណសី មានឈ្មោះថា មោលិនី ។ ក្នុងកាលនោះ ព្រះពោធិសត្វបានជាព្រាហ្មណ៍នាមថា សង្ខ ក្នុងទីក្រុងមោលិនី ទៅដើម្បីលក់ដូរតាមទូក បានជួបនឹងព្រះបច្ចេកពុទ្ធជាម្ចាស់មួយព្រះអង្គក្នុងចន្លោះផ្លូវ លោកកំពុងតែដាន់

នូវផែនដីដ៏ក្តៅធំ ដូចជារងើកភ្លើង ព្រោះខ្យល់និងកំដៅថ្ងៃដ៏ក្តៅពន្ទឹកនិមន្តមក មានចិត្តត្រេកអរថា ស្រែកបុណ្យរបស់អាត្មា មកដល់ហើយ ទើបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គពាក់ស្បែកព្រះបាទនេះ ហើយបាំងឆត្រនិមន្តទៅ ដូច្នេះហើយ ក៏ប្រគេនឆត្រ និងស្បែកព្រះបាទ ហើយទៅកំពង់ហើយចុះទូក ។ ក្នុងថ្ងៃទី ៧ នាវាបានគ្រឿងហើយ ព្រះពោធិសត្វបាននាំបុរសជាឧបដ្ឋាកម្នាក់ទៅយកប្រេងលាបពេញទាំងសរីរៈ ហើយបរិភោគលម្អិតជុំស្ករជាមួយនឹងទឹកដោះរាវ តាមត្រូវការហើយ ឲ្យបុរសឧបដ្ឋាកបរិភោគផង ហើយឡើងកាន់កំពូលនៃសសរក្តោងជាមួយនឹងបុរសឧបដ្ឋាកនោះ លោតផ្លោះឡើងធ្លាក់ទៅក្នុងទីបំផុតប្រមាណ ១ ឧសភប្រារព្ធដើម្បីនឹងឆ្លងសមុទ្រ។ កាលបើឧបាសកនោះកំពុងតែឆ្លងសមុទ្រនោះឯង ៧ ថ្ងៃកន្លងទៅហើយ ។ គ្រានោះនាងទេវីឈ្មោះថា មណីមេខលាដែលថែរក្សានូវសមុទ្រប្រាថ្នានឹងជួយស្រង់ព្រះពោធិសត្វ ទើបនិម្មិតនាវាសម្រេចដោយរតនៈ ពេញទៅដោយរតនៈ ៧ ប្រការ លើកពព្រះធពោធិសិត្វនោះដាក់លើនាវា មិនឱ្យក្រឡេកមើលបុរសជាឧបដ្ឋាកឡើយ ។ ព្រះពោធិសត្វបានឱ្យចំណែកបុណ្យអំពីកល្យាណកម្ម ដែលខ្លួនបានធ្វើហើយដល់ឧបដ្ឋាកនោះ ។ ឧបដ្ឋាកនោះ អនុមោទនាហើយនូវចំណែកបុណ្យនោះ ។ គ្រានោះទេវតាបានឱ្យឧបដ្ឋាក

នោះ ឋិតនៅលើនាវា នាំនាវានោះឆ្ពោះទៅកាន់ទីក្រុងមោលិនី ញុំាងទ្រព្យឱ្យតាំងនៅលើផ្ទះរបស់ព្រះពោធិសត្វ ហើយក៏បាន វិលទៅកាន់វិមានរបស់ខ្លួនវិញភ្លាម ។

ព្រោះហេតុដូច្នោះ ចេតនាជាហេតុអនុមោទនា រមែងជា គុណជាតិ ឱ្យផលក្នុងខណៈនោះបាន ។

(រឿងនេះ លោកពោលហើយក្នុងអដ្ឋកថា សង្ខព្រាហ្មណ៍ជាតក ក្នុងទសកនិបាត)

## រឿងប្រេតជាមាតានៃព្រះសារីបុត្ត

ព្រះសាស្ដា កាលទ្រង់ប្រថាប់នៅវត្តវេឡុវ័ន មហាវិហារ ទ្រង់ប្រារព្ធនាងប្រេតមាតារបស់ព្រះសារីបុត្តត្ថេរ ដោយជាតិទី ៥ អំពីបច្ចុប្បន្នជាតិនេះ ទើបត្រាស់គាថានេះ មានពាក្យចាប់ផ្ដើមថា **នគ្គា ទុព្វណ្ណរូបាសិ** ដូច្នេះ ។

ថ្ងៃមួយ ព្រះសារីបុត្រ ព្រះមហាមោគ្គល្លាន ព្រះអនុរុទ្ធ និង ព្រះកប្បិន បាននៅក្នុងព្រៃមួយកន្លែងមិនឆ្ងាយពីក្រុងរាជគ្រឹះ ។ ក៏សម័យនោះឯង ក្នុងក្រុងពារាណសី មានព្រាហ្មណ៍ម្នាក់ ជា អ្នកមាំមួន មានទ្រព្យច្រើន មានភោគៈច្រើន ដូចជាអណ្ដូង ទីផឹក ស៊ីរបស់សមណព្រាហ្មណ៍ មនុស្សកំព្រាអ្នកធ្វើដំណើរ វណិពក និងយាចក បានឱ្យវត្ថុមានបាយ ទឹក សំពត់ និងទីដេកជាដើម កាលនឹងឱ្យ រមែងបដិបត្តិតាមសេចក្ដីពេញចិត្តគ្រប់យ៉ាង តាម លំដាប់របស់ការឱ្យ មានទឹកលាងជើង និងសំពត់ជូតជើងជាដើម

តាមកាលនឹងតាមសេចក្ដីសមរម្យ ដល់អ្នកដែលមកដល់ហើយៗ ។ ក្នុងវេលាមុនអាហារ បានអង្គាសភិក្ខុទាំងឡាយដោយបាយ និងទឹកជាដើម ដោយគោរព ។ លោកកាលនឹងទៅប្រទេសដទៃ ទើបពោលនឹងភរិយាថា នាងដ៏ចម្រើន នាងកុំធ្វើទានវិធីនេះ តាមដែលបញ្ញត្តិឲ្យសាបសូន្យឡើយ ចូលទៅតាំងទុកដោយគោរព ។ ភរិយាទទួលពាក្យដើម្បីនៅអាស្រ័យ ក៏សម្ដែងសាលាចាស់ដែលចោលទុកខាងក្រោយផ្ទះ ដោយពាក្យថា ពួកលោកចូរនៅក្នុងសាលានេះ ។ កាលអ្នកដំណើរមកក្នុងទីនោះ ដើម្បីត្រូវការបាយ និងទឹកជាដើម ទើបពោលថា ចូរស៊ីគូថ (លាមក) ផឹកមូត្រ (ទឹកនោម) ផឹកលោហិត(ឈាម) ស៊ីខួររបស់មាតាលោក ហើយទើបបញ្ចុះឈ្មោះវត្ថុដែលមិនស្អាត គួរខ្ពើម ហើយស្ដោះទឹកមាត់ពោលរឹងរុះ ។

សម័យតមក នាងធ្វើកាលកិរិយាហើយ ដោយអានុភាពកម្មនោះ ទៅកើតក្នុងកំណើតប្រេត សោយទុក្ខដែលកើតអំពីវចីទុច្ចរិតរបស់ខ្លួន ត្រឡប់រលឹកដល់សេចក្ដីសម្ព័ន្ធគ្នាក្នុងជាតិមុន មានសេចក្ដីប្រាថ្នានឹងមកកាន់សំណាក់របស់ព្រះសារីបុត្ត ទើបដល់ទ្វារវិហារ ។ ទេវតាដែលស្ថិតនៅត្រង់ទ្វារវិហាររបស់ព្រះសារីបុត្តនោះហាមមិនឱ្យចូលវិហារ ។ បានឮថា នាងប្រេតនោះ ធ្លាប់ជាមាតារបស់ព្រះថេរៈក្នុងជាតិទី ៥ អំពីបច្ចុប្បន្នជាតិនេះ ។ ព្រោះ

ដូច្នោះ នាងទើបពោលយ៉ាងនេះថា ខ្ញុំជាមាតារបស់លោកម្ចាស់សារីបុត្តត្ថេរក្នុងជាតិទី ៥ អំពីបច្ចុប្បន្នជាតិ សូមលោកចូរឱ្យខ្ញុំចូលទៅដើម្បីឃើញព្រះថេរៈ ។ ទេវតាបានស្តាប់ដូចនោះ ទើបអនុញ្ញាតឱ្យនាងចូលទៅ នាងគ្រាចូលទៅហើយបានឈរក្នុងទីបំផុតទីចង្ក្រម សម្តែងខ្លួនដល់ព្រះថេរៈ។ ព្រះថេរៈគ្រាបានឃើញនាងប្រេតនោះ ជាអ្នកមានចិត្តដែលសេចក្តីករុណាដាស់តឿន ទើបសួរដោយគាថាថា ម្នាលស្រីស្គម មានធ្មឹងជំនីរគាម នាងជាស្រីអាក្រាត មានរូប មានសម្បុរ អាក្រក់ក្រៃពេក មានខ្លួនស្គាំងស្គម មានខ្លួនរវាមដោយសរសៃ នាងជាអ្វី មកឈរនៅទីនេះ ។

នាងប្រេតនោះ ត្រូវព្រះថេរៈសួរ កាលនឹងឆ្លើយតប ទើបបានពោលគាថា ៥ គាថា សេចក្តីថា អំពីមុនខ្ញុំជាមាតាបង្កើតរបស់លោក ក្នុងជាតិទាំងឡាយដទៃៗ មកកើតក្នុងកំណើតនៃប្រេតពេញប្រៀបដោយសេចក្តីស្រេកឃ្លាន បរិភោគទឹកមាត់ ដែលគេស្តោះចោល ទឹកសម្បោរ ស្លេស្ម ខ្ទាញ់រាវ នៃសាកសព ដែលគេដុត និងឈាមនៃស្ត្រីទាំងឡាយ ដែលសម្រាលកូន និងឈាមនៃដំបៅ និងឈាមដែលជាប់នឹងសរីរៈនៃស្រីនិងបុរស នូវខ្ទុះ និងឈាមនៃដំបៅ និងច្រមុះ និងក្បាលដាច់ មានសេចក្តីស្រេកឃ្លានគ្របសង្កត់ ខ្ញុំបរិភោគនូវខ្ទុះ និងឈាមដែលជាប់នឹងសរីរៈនៃស្រីនិងបុរស នូវខ្ទុះ និងឈាមនៃបសុកសត្វ និងមនុស្សទាំងឡាយ ខ្ញុំ

មិនមានទីពឹងមិនមានទីលំនៅ ដេកតែលើទីស្មសាន ដូចគ្រៃ លោកម្ចាស់ជាបុត្ត សូមលោកម្ចាស់ ឱ្យទានដើម្បីខ្ញុំ លុះឱ្យហើយ ចូរឧទ្ទិសផលដល់ខ្ញុំ គិតធ្វើដូចម្ដេចហ្ន៎ ខ្ញុំគប្បីបានរួចអំពីការ បរិភោគនូវខ្ទុះ និងឈាម ។

ព្រះសារីបុត្តត្ថេរ បានស្ដាប់ដូចនោះហើយ ក្នុងថ្ងៃទីពីរ ទើបហៅព្រះថេរៈ ៣ រូប មានព្រះមហាមោគ្គល្លានត្ថេរជាដើម មកព្រមដោយព្រះថេរៈទាំងនោះ ត្រាច់ទៅបិណ្ឌបាតក្នុងក្រុង រាជគ្រឹះ បានទៅដល់ព្រះរាជនិវេសន៍ របស់ព្រះបាទពិម្ពិសារ ។ ព្រះរាជាឃើញព្រះថេរៈហើយ ទើបសួរដល់ហេតុនៃការមកថា លោកម្ចាស់ លោកមកដើម្បីប្រយោជន៍អ្វី, ព្រះមហាមោគ្គល្លាន ទើបបានទូលរឿងនោះចំពោះព្រះរាជា ព្រះរាជាត្រាស់ថា ញោម ដឹងហើយ ទើបគេចចេញពីព្រះថេរៈបង្គាប់ឱ្យហៅអាមាត្យអ្នក សម្រេចរាជការទ្រង់បញ្ជា អ្នកចូរសាងកុដិ ៤ ខ្នង ក្នុងទីនេះ ដែលបរិបូរណ៌ ដោយម្ញប់និងទឹកដ៏វិចិត្រ មិនឆ្ងាយពីក្រុង និង ក្នុងខាងក្នុងព្រះរាជវាំងឱ្យបែងចែកជា ៣ ចំណែក ដោយមាន សេចក្ដីពិសេស ត្រឹមតែល្មមហើយ ឱ្យទទួលកុដិ ៤ ខ្នង ។ និង ព្រះអង្គឯង ក៏បានស្ដេចទៅក្នុងទីនោះ ទ្រង់បានធ្វើព្រះរាជ ករណីយកិច្ចដែលគួរធ្វើ ។ កាលកុដិសម្រេចហើយ ទើបឱ្យត្រៀម ពលីកម្មទាំងអស់ ចូលទៅតម្កល់បាយទឹក និងសំពត់ជាដើម និង

គ្រឿងបរិក្ខារគ្រប់យ៉ាង ដែលសមគួរដល់ភិក្ខុសង្ឃមកពីទិសទាំង ៤ មានព្រះពុទ្ធជាប្រធាន ហើយប្រគល់ថ្វាយវត្ថុទាំងអស់នោះចំពោះព្រះសារីបុត្តត្ថេរ ។ លំដាប់នោះ ព្រះថេរៈបានថ្វាយវត្ថុទាំងអស់នោះចំពោះភិក្ខុសង្ឃ ដែលមកពីទិសទាំង ៤ មានព្រះពុទ្ធជាប្រធាន ឧទ្ទិសដល់នាងប្រេតនោះ ។

នាងប្រេតនោះ បានអនុមោទនាចំណែកបុណ្យនោះ ហើយកើតក្នុងទេវលោក ជាអ្នកព្រមដោយវត្ថុដែលគួរប្រាថ្នាគ្រប់យ៉ាងក្នុងថ្ងៃតមក ក៏បានចូលទៅរកព្រះមហាមោគ្គល្លានត្ថេរថ្វាយបង្គំហើយឈរ ។ ព្រះថេរៈសាកសួរនាងប្រេតនោះ ។ នាងប្រេតនោះបានពោលហេតុដែលខ្លួនចូលដល់ភាពជាប្រេត និងចូលដល់ភាពជាទេវតាទៀត ។ ដោយហេតុនោះ លោកទើបពោលថា៖

ព្រះអគ្គសាវកមាននាមថា ឧបតិស្សៈ លុះបានស្តាប់ពាក្យនៃនាងប្រេតជាមាតាហើយ មានចិត្តប្រកបដោយករុណាបានហៅព្រះមោគ្គល្លាន ១ ព្រះអនុរុទ្ធ ១ ព្រះកប្បិន ១ ឱ្យធ្វើនូវកុដិទាំងឡាយ ៤ ខ្នង ហើយវេរកុដិផង ឱ្យបាយនិងទឹកផងចំពោះព្រះសង្ឃដែលមកអំពីទិសទាំង ៤ ហើយ ឧទ្ទិសទក្ខិណាទានដល់មាតា ។ វិបាកក៏កើតឡើងក្នុងលំដាប់ដែលឧទ្ទិស ហើយភោជនាហារ ទឹកផឹក និងសំពត់ក៏កើតឡើង នេះជាផលនៃ

ទក្ខិណាទាន លំដាប់នោះ ស្រីនោះមានរាងកាយស្អាត មានសំពត់ស្លៀកពាក់ស្អាតបាត ទ្រទ្រង់នូវសំពត់ដ៏ឧត្តមជាងសំពត់ដែលកើតក្នុងដែនកាសី មានគ្រឿងវត្ថាភរណៈដ៏វិចិត្រ បានចូលទៅរកព្រះកោលិតៈ ។

លំដាប់នោះ ព្រះមហាមោគ្គល្លាន សួរនាងប្រេតនោះថា

ម្នាលនាងទេវធីតា នាងមានសម្បុរល្អ មកឈរនៅទីនេះ ភ្លឺស្វាងទូទៅសព្វទិសទាំងឡាយ ដូចជាផ្កាយព្រឹក ឯសម្បុរប្រាកដដូច្នោះកើតឡើងដល់នាង ដោយហេតុដូចម្តេច ផលនៃសុចរិតសម្រេចដល់នាងក្នុងទីនេះ ដោយហេតុដូចម្តេច បានជាភោគៈណានីមួយ ដែលជាទីពេញចិត្តកើតឡើងដល់នាង ។

ម្នាលនាងទេវធីតា មានអានុភាពច្រើន យើងសូមសួរនាង នាងកាលកើតជាមនុស្ស តើបានធ្វើបុណ្យដូចម្តេច នាងជាទេវធីតា មានអានុភាពភ្លឺផ្ទេកយ៉ាងនេះ ទាំងសម្បុរនាងក៏ភ្លឺសព្វទិស ដោយបុញ្ញកម្មដូចម្តេច ។

លំដាប់នោះ នាងប្រេតទើបតបដោយន័យមានជាដើមថា អំពីមុន ខ្ញុំជាមាតារបស់ព្រះសារីបុត្ត ។ ពាក្យដែលនៅសល់មានន័យដូចពោលហើយនុ៎ះឯង ។

លំដាប់នោះ ព្រះមហាមោគ្គល្លានត្ថេរ បានក្រាបទូលរឿងនោះ ចំពោះព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ធ្វើរឿង

នោះឱ្យជាអត្ថុប្បត្តិហេតុហើយ ទ្រង់សម្តែងធម៌ដល់បរិស័ទដែលចូលដល់ព្រមហើយ ។ ទេសនានោះ បានមានប្រយោជន៍ដល់មហាជន ដូច្នោះឯង ។ (ចាកអដ្ឋកថា បរមត្ថទីបនី)

## បុណ្យទក្ខិណានុប្បទាន

**បុណ្យទក្ខិណានុប្បទាន** ជាបុណ្យមួយធ្វើឡើងដើម្បីឧទ្ទិសកុសលជូនដល់អ្នកដែលចែកឋានទៅ ។ តាមធម្មតាមនុស្សណាម្នាក់ មានបំណងជូនវត្ថុដល់អ្នកណាម្នាក់ គេអាចជូនដោយកាយ ឬដោយវាចា, នេះជូនចំពោះអ្នកនៅរស់ ។ ប៉ុន្តែចំពោះអ្នកដែលស្លាប់ទៅពុំអាចជូនបែបនេះបានឡើយ គឺត្រូវធ្វើបុណ្យកុសល មានធ្វើទាន សមាទានសីលជាដើម ហើយតាំងចិត្តជូនទៅ ដែលហៅថា បុណ្យទក្ខិណានុប្បទាននេះឯង ។ បុណ្យទក្ខិណានុប្បទាននេះ ត្រូវធ្វើឱ្យត្រឹមត្រូវ ទើបសម្រេចផលដល់អ្នកដែលចែកឋានទៅដោយអង្គ ៣ ប្រការគឺៈ

**១-ត្រូវធ្វើបុណ្យកុសល** មានការធ្វើទាន រក្សាសីល ភាវនាជាដើម ជាពិសេសត្រូវធ្វើទានចំពោះអ្នកមានសីល ដែលក្នុងបាលីថា **សង្ឃម្ហិ សុបតិដ្ឋិតា** ប្រែថា ទានបានដំកល់ល្អហើយក្នុងព្រះសង្ឃ ។

**២-ឧទ្ទិសេន** ប្រែថា ដោយការតាំងចិត្តជូនកុសលទៅ ។ បានសេចក្តីថា ត្រូវតាំងចិត្តឧទ្ទិសកុសលដែលបានធ្វើនោះជូន

ដល់អ្នកដែលចែកស្ថានទៅ ទើបអ្នកស្លាប់មានសិទ្ធិទទួល ។ បើពុំបានឧទ្ទិសជូនទៅទេ អ្នកស្លាប់គ្មានសិទ្ធិទទួលឡើយ ប្រៀបដូចជនណាម្នាក់ ពុំហ៊ានយកវត្ថុ ដែលគេពុំបានឱ្យដោយកាយ ឬដោយវាចា បើយកទុកជាបទលួច ។ ការឧទ្ទិសកុសលគឺ ឧទ្ទិសតាមមនោទ្វារ គឺផ្លូវចិត្តទុកជាបានការ ។ បើបញ្ចេញវាចាដូចជាធម៌វេរថែមទៀត ក៏រឹតតែល្អ មានអ្នកខ្លះសរសេរឈ្មោះ អ្នកស្លាប់ព្រោះខ្លាចភ្លេចនឹកពុំអស់ ។

***៣-អនុមោទនេន*** គឺអ្នកស្លាប់ដែលបានទៅកើតជាអ្វីមួយនោះអាចទទួលត្រេកអរបានផង ។ ក្នុងតិរោកុឌ្ឌសូត្របញ្ជាក់ថាសត្វដែលអាចទទួលផលដែលញាតិមិត្តឧទ្ទិសទៅឱ្យ ភាគច្រើនបានដល់ប្រេត ៣ ពួក មានប្រេតឈ្មោះ បរទត្តូបជីវិកប្រេតប្រែថា ប្រេតរស់នៅដោយសារអំណោយផលដែលញាតិមិត្តឧទ្ទិសទៅឱ្យជាដើម នេះជាអង្គ ៣ យ៉ាង នៃការធ្វើបុណ្យទក្ខិណានុប្បទាន ។ មានទំនៀមទម្លាប់ក្រៅពុទ្ធសាសនាមួយ គឺការសែនព្រេនដោយគេរៀបចំបាយ ទឹក នំ ចំណី ហើយនិយាយអញ្ជើញអ្នកដែលចែកស្ថានទៅឱ្យមកសេពសោយ ។ តាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ការសែនបែបនេះ អ្នកដែលស្លាប់ទៅពុំអាចមកបរិភោគភោជនាហារនោះបានឡើយ ព្រោះអ្នកស្លាប់ទៅ បានទៅកើតជាអ្វីមួយមានអាហារផ្សេងៗគ្នា ប៉ុន្តែបានផល

ដល់អ្នកធ្វើខ្លះត្រង់នឹកគុណដល់អ្នកស្លាប់ ។

ចំណែកព្រះសង្ឃសូត្រធម៌ធម្មសង្វេគ ដែលពុទ្ធបរិស័ទនិយមហៅថា ធម៌បង្សុកូលនោះ គ្រាត់តែជាកិច្ចអនុមោទនាទៅលើអង្គទាំង ៣ នៃទក្ខិណានុប្បទាននោះប៉ុណ្ណោះ ។ តាមពិតការសូត្រធម៌ធម្មសំវេគ ដែលហៅថា ធម៌បង្សុកូលនោះ មានគោលបំណងពិសេសឱ្យអ្នកនៅរស់ ដែលជាសមាជិកគ្រួសាររបស់អ្នកស្លាប់ ពិចារណាឱ្យឃើញភាពពុំទៀងនៃជីវិត ដូចព្រះសង្ឃសូត្រធម៌ថា **អនិច្ចា វត សង្ខារា** ។ល។ ប្រែថា សង្ខារទាំងឡាយ ពុំទៀងមែនពិត មានកិរិយាកើតឡើងហើយ វិនាសទៅវិញជាធម្មតា លុះតែរលត់នូវសង្ខារទាំងឡាយនោះហើយ ទើបបាននូវសេចក្តីសុខគ្រប់យ៉ាង ។ សង្ខារក្នុងធម៌នេះ សំដៅយកខន្ធ ៥ របស់មនុស្សសត្វ ។ អ្នកដែលបានធ្វើបុណ្យឧទ្ទិសទៅនេះរមែងមានចិត្តជ្រះថ្លា នៅពេលធ្វើបុណ្យហើយបានបុណ្យ ម្យ៉ាងទៀត គឺត្រង់នឹកដល់គុណអ្នកដែលចែកស្ថានទៅ ។ ក្នុងខទី ៥ នៃធម៌ ដែលបុត្តធីតាប្រុសស្រីត្រូវតបគុណចំពោះមាតាបិតាថា បន្ទាប់ពីមាតាបិតាអនិច្ចកម្មទៅ បុត្រធីតាប្រុសស្រីត្រូវធ្វើបុណ្យទក្ខិណានុប្បទានឧទ្ទិសកុសលជូនគាត់ ។ ចំណែកសមាជិកគ្រួសារដែលស្លាប់ទៅក្រៅពីមាតាបិតា ក៏ក្រុមគ្រួសារត្រូវឧទ្ទិសកុសលជូនទៅដូចគ្នា ។ ការឧទ្ទិសកុសលនេះ មិនត្រឹមតែញាតិមិត្តរបស់

ខ្លួន ទើបឧទ្ទិសកុសលបាននោះទេ អាចក្រាលចិត្តឱ្យទូលាយ ឧទ្ទិសជូនទៅគ្រប់សព្វសត្វទាំងអស់ ដូចការសូត្រធម៌ **យំ កិញ្ចិ កុសលកម្ម ។** ការឧទ្ទិសកុសលនេះក្នុងឧត្តមគតិថា ទោះបីក្រុមគ្រួសារស្លាប់ទៅ ហើយក៏នៅតែនឹក រលឹកគុណពុំភ្លេច ហើយជាការជួយសង្គ្រោះ ក្រែងអ្នកស្លាប់ទៅនោះ ទទួលរងទុក្ខវេទនាក្នុងភពណាមួយ ជាការឧទ្ទិសជួយរំលែកទុក្ខដែលចាត់ទុកថា ជាការតបគុណចំពោះអ្នកស្លាប់ ។

## **វិហារវិមាន**

វិហារវិមាន មានគាថាថា **អភិក្កន្តេន វណ្ណេន** ជាដើម ។ វិហារវិមាននោះកើតឡើងបានយ៉ាងណា ?

ព្រះមានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន នាក្រុងសាវត្ថី ។ សម័យនោះមហាឧបាសិកាវិសាខា ព្រមទាំងមិត្តនិងបរិវារជននាំគ្នាងូតទឹក តែងខ្លួនដើម្បីនឹងដើរកំសាន្តក្នុងថ្ងៃរីករាយមួយ នាងបរិភោគភោជនយ៉ាងប្រណីត ហើយបានប្រដាប់ដោយអាភរណមហាលតាប្រសាទ នឹងលោមព័ទ្ធទៅដោយមិត្តស្ត្រីប្រមាណ ៥០០នាក់ ចេញអំពីផ្ទះដោយឥស្សរិយយសដ៏ធំក្រៃលែង ដោយការកំណាត់ក្បួនយ៉ាងធំ កំពុងដើរតម្រង់ទៅកាន់ឧទ្យាន ដោយគិតថា ប្រយោជន៍អ្វីរបស់យើងដោយការដើរលេង ឥតប្រយោជន៍ដូចក្មេងស្រីល្ងង់ៗនោះ យើងនឹងដើរទៅកាន់វត្ត ថ្វាយបង្គំព្រះ

មានព្រះភាគជាម្ចាស់ និងក្រាបថ្វាយបង្គំលោកម្ចាស់ទាំងឡាយ ដែលជាទីចម្រើននៃចិត្ត ហើយនឹងអង្គុយស្តាប់ព្រះធម៌, លុះទៅដល់វត្តហើយ បានឈប់នៅទីកន្លែងមួយ បានដោះអាវមហាលតាប្រាសាទ ប្រគល់ទុកក្នុងដៃរបស់ទាសីម្នាក់ ហើយបានថ្វាយបង្គំព្រះមានព្រះភាគជាម្ចាស់ រួចអង្គុយក្នុងទីដ៏សមគួរ ព្រះមានព្រះភាគជាម្ចាស់ទ្រង់បានសម្តែងធម៌ដល់វិសាខាមហាឧបាសិកានោះ។

នាងស្តាប់ធម៌ហើយ ថ្វាយបង្គំព្រះមានព្រះភាគជាម្ចាស់ ហើយធ្វើប្រទក្សិណ ទាំងក្រាបថ្វាយបង្គំពួកភិក្ខុទាំងឡាយ ហើយបានចៀសចេញអំពីវត្តបានបន្តិច បាននិយាយនឹងស្ត្រីជាទាសីថា នាងចូរយកអាវខ្ញុំមក, ខ្ញុំនឹងប្រដាប់គ្រឿងប្រដាប់ ។ ទាសីនោះបានវេចគ្រឿងប្រដាប់ដាក់ទុកនៅទីវត្តហើយ ទើបបានដើរទៅកាន់ទីកន្លែងស្តាប់ព្រះធម៌ ឥឡូវនេះបានភ្លេចនៅក្នុងទីនោះ ទាសីនោះមានប្រាថ្នានឹងត្រឡប់ទៅយក ទើបនឹកឃើញថា និយាយថា ខ្ញុំបានភ្លេចនៅឯវត្តបាត់ហើយ សូមអ្នកនាងម្ចាស់ឈប់សិន ខ្ញុំនឹងត្រឡប់ទៅយក ។ គ្រានោះនាងវិសាខាបាននិយាយថា នែ៎នាង បើនាងភ្លេចគ្រឿងប្រដាប់នោះនៅក្នុងវត្ត ខ្ញុំនឹងបរិច្ចាគគ្រឿងប្រដាប់នោះកសាងវត្តនោះតែម្តង ពេលនោះនាងវិសាខាបានទៅកាន់វត្ត ហើយក្រាបទូលនូវសេចក្តីប្រាថ្នារបស់ខ្លួនថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់នឹងសាងវត្តសូមព្រះមានព្រះភាគមេត្តា

ទទួលផងចុះ ព្រះមានព្រះភាគទទួលដោយតុណ្ហីភាព ។

នាងវិសាខាលះបង់នូវគ្រឿងប្រដាប់នោះ ដែលមានតម្លៃដល់ទៅដល់ប្រាំបួនកោដិប្រាំពីរពាន់ សាងវត្តមួយយ៉ាងធំ សមគួរជាទីគង់ប្រថាប់នៃព្រះមានព្រះភាគ និងជាទីគង់នៅនៃភិក្ខុសង្ឃ មានបន្ទប់ ១០០០ គឺនៅជាន់ខាងក្រោម ៥០០ បន្ទន់ នៅខាងលើ ៥០០ បន្ទប់ ប្រៀបដូចជាទេពវិមាន មានភូមិផ្ទៃដូចរតនាគារកែវមណី មានចំណែករបស់បន្ទប់ជាដើមគឺ ជញ្ជាំង សសរ ធ្នឹម គ្រឿងដំបូល ចុងកំពូលនៃវត្ត ទ្វារ បង្អួច និងជណ្ដើរ ដែលព្រះមហាមោគ្គល្លានត្ថេរៈ អ្នកគ្រប់គ្រងការសាងសងចាត់ចែងយ៉ាងល្អ ការងារបូកកំបោរក៏សម្រិតសម្រាំងធ្វើយ៉ាងល្អពេញចិត្តវិចិត្រទៅដោយចិត្រកម្ម មានមាលាកម្ម ក្បាច់ក្បូរផ្កាឈើ និងទីលតាកម្ម ក្បាច់វល្លិ៍ឈើជាដើម ដែលប្រដាប់តាក់តែងយ៉ាងល្អស្អាត និងកសាងប្រាសាទរហោដ្ឋានមួយពាន់ ជាបរិវាររបស់វត្តនោះ និងសាងកុដិមណ្ឌប និងទីចង្ក្រមជាដើម ជាបរិវារវត្តនោះ ដោយប្រើពេលវេលាអស់ ៩ ខែ ទើបសាងវត្តរួច កាលសាងវត្តរួចស្រេចហើយ នាងវិសាខាបានចំណាយប្រាក់ធ្ងន់អស់ដល់ទៅ ប្រាំបួនកោដិ នាងនិងស្ត្រីជាមិត្តសម្លាញ់ប្រមាណ ៥០០ នាក់ឡើងលើប្រាសាទ បានឃើញលក្ខណៈសម្បត្តិរបស់វត្តនោះ ល្អពេញចិត្តហើយបាននិយាយនឹងមិត្តសម្លាញ់ទាំងឡាយថា កាលខ្ញុំសាងវត្ត

នេះ ស្អាតយ៉ាងនេះ សូមអ្នកទាំងឡាយ ចូលត្រេកអរអនុមោទនា ចំពោះបុណ្យដែលខ្ញុំបានខិតខំខ្វល់ខ្វាយនេះផងចុះ ខ្ញុំសូមជូន ចំណែកបុណ្យដល់ពួកអ្នកទាំងឡាយ ។ គ្រានោះ មិត្តស្ត្រីទាំង ឡាយ មានចិត្តជ្រះថ្លាបាននាំគ្នាអនុមោទនាថា **សាធុ សាធុ សាធុ** ប្រែថា ល្អពិតមែនៗ ល្អពិតមែនៗ ។

បណ្ដាមិត្តស្ត្រីទាំងនោះ មានមិត្តឧបាសិកាម្នាក់ បានដាក់ ចិត្តដល់ការផ្សាយចំណែកបុណ្យឱ្យជាពិសេស តមកមិនយូរប៉ុន្មាន នាងបានស្លាប់ ទៅកើតនៅឋានតាវត្តិង្ស ដោយបុញ្ញានុភាព របស់នាងបានប្រាកដវិមានមួយយ៉ាងធំ ធំទូលាយ និងមានកំពស់ ១៦ យោជន៍ប្រដាប់ដោយបន្ទប់កំពែងឧទ្យាន និងស្រះបោក្ខរណី ជាដើម រសាត់អណ្ដែតទៅលើអាកាស មានរស្មីផ្សាយទៅបាន រយយោជន៍ទេពអប្សរនោះកាលដើរទៅក៏ទៅទាំងវិមាន,សម្រាប់ ឧបាសិកាវិសាខា ព្រោះមានចាគៈបរិបូណ៌និងមានសទ្ធាបរិបូណ៌ ទើបទៅកើតនៅឋាននិម្មារតី បានតំណែងជាអគ្គមហេសីនៃស្ដេច សុនិមិត្តទេវរាជ, គ្រានោះព្រះអនុរុទ្ធត្ថេរៈ ត្រាច់ចារិកទៅកាន់ ទេវលោក ពិនិត្យបានឃើញមិត្តស្ត្រីរបស់នាងវិសាខាកើតក្នុង ឋានសួគ៌ ទើបបានសាកសួរដោយគាថាពួកនេះថាៈ

ព្រះអនុរុទ្ធត្ថេរសួរថា ម្នាលទេវធីតា នាងមានសម្បុរដ៏រុង រឿង ។ល។ ដូចផ្កាយព្រឹក កាលដែលនាងកំពុងរាំនោះ សំឡេង

ទិព្វទាំងឡាយគួរស្តាប់ គួររីករាយនៃចិត្ត រមែងលាន់ឮអំពីអវយវៈតូចធំ ដោយសព្វគ្រប់ កាលដែលនាងកំពុងរាំនោះក្លិនទិព្វទាំងឡាយៗ មានក្លិនក្រអូប ជាទីរីករាយនៃចិត្ត រមែងផ្សាយចេញអំពីអវយវៈតូចធំ ដោយសព្វគ្រប់ កាលនាងផាកកាយ គ្រឿងប្រដាប់ទាំងឡាយឮដ៏ផ្គងសក់ ក៏ឮសូរគឹកកង ដូចតូរ្យតន្ត្រីប្រកបដោយអង្គ ៥ គ្រឿងប្រដាប់ត្រចៀក ត្រូវខ្យល់បក់មកប៉ះ ក៏កម្រើកដោយខ្យល់ ឮសូរគឹកកង ដូចតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ផ្កាឮដ៏សិរ្យៈរបស់នាងមានក្លិនក្រអូប ជាទីរីករាយនៃចិត្ត ក្លិនផ្កាកម្រងនោះ រមែងផ្សាយទៅសព្វទិសដូចដើមឱឡោក នាងតែងធុំក្លិនក្រអូបនោះ តែងឃើញរូបដែលមិនមែនជារបស់មនុស្ស ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

ទេវតាឆ្លើយថា បពិត្រព្រះអនុរុទ្ធដ៏ចម្រើន នាងវិសាខា ជាសំឡាញ់របស់ខ្ញុំ បានឱ្យជាងធ្វើមហាវិហារ ទៀបក្រុងសាវត្ថី ឧទ្ទិសចំពោះសង្ឃ ខ្ញុំជ្រះថ្លារីករាយចំពោះវិហារនោះ ព្រោះឃើញនូវផ្ទះ គឺវិហារជាទីស្រឡាញ់នោះ ទើបវិមានដែលខ្ញុំបានហើយដោយអនុមោទនាដ៏បរិសុទ្ធនោះឯង ជាវត្ថុអស្ចារ្យ គួររមិលមើលក៏ខ្ពស់ទៅដ៏អាកាសអស់ ១៦ យោជន៍ជុំវិញ ដោយបុញ្ញារិទ្ធិនៃខ្ញុំ ផ្ទះកំពូលជាលំនៅរបស់ខ្ញុំ ដូចគេចែកដោយចំណែកស្មើគ្នា រុងរឿងភ្លឺទូទៅអស់ ១០០ យោជន៍ជុំវិញ ឯស្រះបោរក្ខរណី

ទាំងឡាយរបស់ខ្ញុំ ក្នុងទីនេះដែលពួកត្រីទិព្វនៅអាស្រ័យហើយ មានទឹករងថ្មាក្រាលដោយខ្សាច់មាស ដេរដាសដោយឈូកផ្សេងៗ ធ្លូកដោយឈូកសទាំងឡាយ មានក្លិនក្រអូបជាទីគាប់ចិត្ត ដែលខ្យល់បក់ផ្សាយទៅ ដើមព្រីង ខ្នុរ ត្នោត ដូង ព្រៃ និងឈើផ្សេងៗ ទាំងឡាយ ដុះជិតលំនៅខាងក្នុងមិនបាច់ដាំឡើយ វិមាននោះសឹងរងំដោយតូរ្យតន្ត្រីផ្សេងៗ គឹកកងដោយពួកស្រីអប្សរ ទោះជនណាឃើញខ្ញុំក្នុងការយល់សប្តិ ជននោះឯងគង់ត្រេកអរវិមានបែបនេះជាទីអស្ចារ្យ គួររមិលមើល ភ្លឺព្រោងព្រាតដោយសព្វគ្រប់កើតឡើងដោយបុញ្ញកម្មទាំងឡាយរបស់ខ្ញុំ បុគ្គលគួរធ្វើនូវបុណ្យទាំងឡាយ ។

ព្រះអនុរុទ្ធត្ថេរសួរថា វិមានដែលនាងបានហើយ ដោយអនុមោទនាដ៏បរិសុទ្ធនោះឯង ជាទីអស្ចារ្យ គួររមិលមើល ម្យ៉ាងទៀត នារីណាបានឱ្យនូវទាន នាងចូរប្រាប់នូវគតិរបស់នារីនោះតើទៅកើតក្នុងទីណា ។

ទេវតាឆ្លើយថា បពិត្រលោកដ៏ចម្រើន ស្រីសំឡាញ់របស់ខ្ញុំណាបានឱ្យជាងធ្វើមហាវិហារដើម្បីសង្ឃ ស្រីសំឡាញ់នោះ គឺនាងវិសាខា ជាស្រីមានធម៌ ដឹងច្បាស់ បានឲ្យទានហើយ បានទៅកើតក្នុងទេវលោកជាន់និម្មានរតី បានជាបជាបតីនៃទេវរាជឈ្មោះសុនិម្មិត លោកម្ចាស់សួររកនូវនារីណាថា នារីនោះទៅ

កើតក្នុងទីណា ផលនៃកម្មរបស់នារីនោះ មិនគប្បីគិតឡើយ ។

បពិត្រលោកដ៏ចម្រើន ខ្ញុំបានដោះស្រាយតាមសេចក្តីពិតមិនប្រែប្រួល ព្រោះហេតុនោះ លោកម្ចាស់ ចូរបបួលពួកជនដទៃថា អ្នកទាំងឡាយ ចូរត្រេកអរឱ្យទានចំពោះសង្ឃផង អ្នកទាំងឡាយចូរមានចិត្តជ្រះថ្លាស្តាប់ធម៌ផង ការបានអត្តភាពជាមនុស្សដែលគេកម្របានដោយងាយ អ្នកទាំងឡាយក៏បានហើយ ព្រះពុទ្ធមានសំឡេងដូចព្រហ្ម មានព្រះចម្មាដូចមាស ជាអធិបតីក្នុងផ្លូវ បានសម្តែងនូវទានជាផ្លូវណា ទក្ខិណាទានដែលបុគ្គលឲ្យហើយចំពោះសង្ឃណា ជាទានមានផលច្រើន អ្នកទាំងឡាយចូរត្រេកអរឲ្យទានទាំងឡាយចំពោះសង្ឃ(នោះ)ចុះ បុគ្គលទាំងឡាយណា ៨ ពួក ដែលសប្បុរសទាំងឡាយសរសើរហើយ បើរាប់ជាគូបាន ៤ គូ បុគ្គលទាំងឡាយនោះ ជាសាវ័កនៃព្រះសុគតលោកគួរដល់ទក្ខិណាទាន ទានទាំងឡាយដែលបុគ្គលឱ្យហើយចំពោះទក្ខិណេយ្យបុគ្គលទាំងឡាយនោះ ជាទានមានផលច្រើន បុគ្គល ៤ ពួកតាំងនៅក្នុងមគ្គ បុគ្គល ៤ ពួកតាំងនៅក្នុងផល នេះឈ្មោះថា ព្រះសង្ឃលោកប្រតិបត្តិត្រង់ ប្រកបដោយបញ្ញា និងសីល បុណ្យឱ្យផលក្នុងបច្ចុប្បន្ន ដែលពួកសត្វជាមនុស្សប្រាថ្នានូវបុណ្យ កាលបូជា កាលធ្វើ បានឱ្យហើយចំពោះសង្ឃ ជាទានមានផលច្រើន ព្រោះថា ព្រះសង្ឃនុ៎ះ ជាព្រះសង្ឃមានគុណធំ

ទូលាយ ព្រះសង្ឃនុ៎ះ ដូចជាសាគរដែលទ្រទ្រង់នូវទឹក មានជម្រៅរាប់មិនបាន ពួកសាវ័កអ្នកមានសេចក្តីព្យាយាម ប្រសើរជាងនរៈទាំងនេះ ជាអ្នកប្រសើរ រមែងពិត ជាអ្នកធ្វើនូវពន្លឺ គឺញាណសម្តែងនូវធម៌ពួកសត្វណាបានឱ្យឧទ្ទិសចំពោះព្រះ សង្ឃ (ទាននោះ)ឈ្មោះថា ពួកសត្វទាំងនោះបានឱ្យល្អហើយ បូជាតូចល្អហើយ បូជាធំល្អហើយសង្ឃគតាទក្ខិណាទាននោះ ដែលបុគ្គលតម្កល់ល្អហើយ ជាទានមានផលច្រើន ដែលព្រះពុទ្ធទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់ត្រាស់សរសើរហើយថា ជនទាំងឡាយណាកាលរឭករឿយៗនូវបុណ្យប្រាកដដូច្នោះ រមែងកើតសេចក្តីត្រេកអរ ត្រាច់រង្គាត់ទៅក្នុងលោក ជនទាំងនោះកម្ចាត់បង់នូវមន្ទិល គឺសេចក្តីកំណាញ់ ព្រមទាំងឫស ជាអ្នកមិនមានគេតិះដៀលបាន រមែងទៅកាន់ឋានសួគ៌ ។ (ព្រះត្រៃបិដកលេខ ៥៥ទំព័រ ៩១)

## ទ្វារបាលវិមាន

ទ្វារបាលវិមាន មានគាថា ថា **ឧច្ចមិទំ មណិថូណំ** ជាដើម ។ ទ្វារបាលវិមានកើតឡើងយ៉ាងណា?

ព្រះមានព្រះភាគ កាលគង់នៅវត្តវេឡុវ័ន ក្រុងរាជគ្រឹះ, សម័យនោះ មានឧបាសកមួយនាក់ នៅក្នុងក្រុងរាជគ្រឹះ បានថ្វាយនិច្ចភត្ត ៤ ពេលដល់ព្រះសង្ឃ ផ្ទះរបស់គេស្ថិតនៅឯខាងចុងភូមិ ហើយផ្ទះរបស់គាត់ភាគច្រើន គឺបិទទ្វារ ព្រោះខ្លាចពួក

ចោរ ពួកភិក្ខុទាំងឡាយដែលនិមន្តទៅបិណ្ឌបាត ពេលខ្លះមិនបាននូវភត្តក៏នាំគ្នាត្រឡប់មកវិញ ព្រោះទ្វារបិតជិត ឧបាសកនិយាយនឹងភរិយាថា អូនសម្លាញ់ អូនបានថ្វាយភិក្ខាដល់លោកម្ចាស់ទាំងឡាយ ដោយគោរពដែលឬទេ ? ភរិយានិយាយថា លោកម្ចាស់ទាំងឡាយមិនបាននិមន្តមកអស់ច្រើនថ្ងៃ ហើយឧបាសកបាននិយាយទៀតថា តើព្រោះហេតុអ្វី ? ភរិយានិយាយតបថា ព្រោះលោកឃើញទ្វារបិត, គ្រាឧបាសកបានស្តាប់ពាក្យនោះហើយ គាត់ស្លុតណាស់ ទើបបានតែងតាំងនូវបុរសមួយឱ្យជាអ្នកយាមទ្វារ ហើយគាត់បានបញ្ជាថា ចាប់តាំងអំពីថ្ងៃនេះទៅ លោកចូរអង្គុយយាមទ្វារ ហើយពេលឃើញលោកម្ចាស់ និមន្តមកវេលាណា ចូរនិមន្តលោកឱ្យចូលទៅក្នុងផ្ទះវេលានោះហើយ ចូរដឹងនូវកិច្ចដែលត្រូវធ្វើទាំងពួង មានការទទួលបាត្រនិងក្រាលអាសនៈជាដើម ដល់លោកម្ចាស់ទាំងឡាយ បុរសនោះក៏បានទទួលពាក្យថា **សាធុ** គាត់បានធ្វើតាមពាក្យបញ្ជានោះ និងបានស្តាប់ធម៌នៅក្នុងសម្នាក់នៃភិក្ខុទាំងឡាយ កើតសទ្ធាជឿកម្មនិងផលនៃកម្ម បានតាំងនៅក្នុងសរណៈ និងសីលទាំងឡាយ បានទំនុកបម្រុងភិក្ខុទាំងឡាយដោយគោរព ។

វេលាតមក ឧបាសកអ្នកដែលបានថ្វាយនិច្ចភត្ត ស្លាប់ទៅបានកើតនៅឋានសួគ៌ជាន់យាមា, ចំណែកអ្នកយាមទ្វារទំនុក

បម្រុងភិក្ខុសង្ឃដោយ សេចក្តីគោរព លុះស្លាប់ទៅបានកើតនៅឋានតាវត្តិង្ស ព្រោះមានសេចក្តីខ្វល់ខ្វាយក្នុងការបរិច្ចាគទានរបស់អ្នកដទៃ និងព្រោះគាត់បានអនុមោទនាសម្បត្តិគ្រប់យ៉ាងមានវិមានមាសទំហំ ១២ យោជន៍ជាដើមរបស់គេ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងកក្កដវិមាននោះឯង ។ គាថាដែលសម្តែងពាក្យសួរនិងឆ្លើយ មានមកយ៉ាងនេះ

ព្រះមោគ្គល្លានសួរថា វិមានដ៏ខ្ពស់នេះ មានសសរធ្វើអំពីកែវមណី មានទំហំជុំវិញ ១២ យោជន៍ មានផ្ទះកំពូល ៧០០ ដ៏លើសលប់ ដែលមានសសរជាវិការៈនៃកែវពិទូរ្យ ក្រាលកម្រាលដ៏ល្អ(ក្តារមាស)ជាផ្ទះកំពូលដ៏ល្អ ខ្លួនអ្នកតែងនៅក្រេបផឹកទាំងទំពាស៊ីក្នុងវិមាននោះ ពិណទិព្វ មានសម្លេងពីរោះ រមែងលាន់ឮកាមគុណ ៥ មានរសជាទិព្វ ទាំងពួកនារី ស្អិតស្អាងកាយដោយគ្រឿងមាស តែងរាំនៅក្នុងវិមាននោះ សម្បុររបស់អ្នកប្រាកដដូច្នោះ តើដោយបុញ្ញកម្មដូចម្តេច ទិព្វសម្បត្តិសម្រេចដល់អ្នកក្នុងទីនេះផង ភោគៈទាំងឡាយនីមួយ ជាទីពេញចិត្ត ភោគៈទាំងនោះក៏កើតឡើងដល់អ្នកផង តើដោយបុញ្ញកម្មដូចម្តេច, ម្នាលទេវតា អ្នកមានអានុភាពច្រើន អាត្មាសូមសួរអ្នក អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស តើដោយបុញ្ញកម្មដូចម្តេច ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ឆ្លើយប្រាប់នូវផលនៃបុញ្ញកម្មនេះថាៈ

ខ្ញុំមានអាយុមួយពាន់ឆ្នាំទិព្វ (ព្រោះ)ពាក្យដែលខ្ញុំពោលដោយវាចា (ដោយសេចក្តីគោរព) ដែលខ្ញុំឱ្យប្រព្រឹត្តទៅហើយដោយចិត្ត, បុគ្គលមានបុញ្ញកម្ម ដោយហេតុត្រឹមតែការពោលនឹងការជ្រះថ្លាប៉ុណ្ណោះ រមែងបរិបូណ៌ដោយកាមជាទិព្វស្ថិតនៅ (អស់កាលយូរ) សម្បុររបស់ខ្ញុំប្រាកដដូច្នោះ ដោយបុញ្ញកម្មនោះខ្ញុំមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់សព្វទិស ។

## ស្វាមីរបស់ធិតានៃកិដុម្ពីក៏មានកាយក្រអូបមាត់ក្រអូប

នៅក្នុងអដ្ឋកថាមនោរថបូរណី លោកបានសម្តែងអំពីក្លិនខ្លួននៃស្វាមីស្ត្រីម្នាក់ មានក្លិនចន្ទន៍ផ្សាយចេញពីព្រះកាយ និងក្លិនឧប្បល(ផ្កាឈូក)ផ្សាយចេញពីមាត់ រឿងនេះគួរនាំមកសម្តែងក៏ក្នុងសេចក្តីនេះ គប្បីជ្រាបរឿងដូចតទៅនេះ៖

បានឮថា ស្វាមីរបស់ធីតានៃកុដុម្ពីក៏ម្នាក់ ក្នុងក្រុងសាវត្ថីស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តា គិតថា យើងជាគ្រហស្ថមិនអាចនឹងបំពេញធម៌នេះបាន ទើបបួសក្នុងសម្នាក់របស់ព្រះបិណ្ឌបាតិកត្ថេរ (ព្រះថេរៈអ្នកកាន់ត្រាច់បិណ្ឌបាតជាវត្ត)មួយ

រូប ។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់ជ្រាបភរិយារបស់គេថា ស្រីម្នាក់នេះមិនមានស្វាមី ទើបបង្គាប់ឱ្យអ្នកនាំមកនៅក្នុងព្រះរាជវាំង ថ្ងៃមួយ ទ្រង់កាន់យកបាច់ផ្កាឧប្បល-សមួយក្តាប់ស្តេចចូលទៅក្នុងព្រះរាជវាំង ទ្រង់ប្រទានផ្កាឧប្បលដល់ស្រីអ្នកអត់ផ្កា ។ កាលបែងចែកគ្នា ផ្កាឧប្បល ២ ទង បានដល់ដៃរបស់ស្រីនោះ ។ ស្រីនោះសម្តែងអាការរីករាយ ហិតហើយក៏យំ ។ ព្រះរាជាទ្រង់ឃើញអាការទាំង ២ របស់នាង ទើបបង្គាប់ឱ្យហៅនាងមកត្រាស់សួរ ។ ចំណែកនាងក្រាបទូលហេតុដែលខ្លួនត្រេកអរនិងស្រែកយំឱ្យទ្រង់ជ្រាប ។ សូម្បីកាលនាងក្រាបទូលដល់គ្រាទី ៣ ព្រះរាជាទ្រង់មិនជឿ ថ្ងៃរះឡើង ទើបបង្គាប់ឱ្យមនុស្សយករបស់ក្រអូប ដែលមានក្លិនយ៉ាងល្អ មានរបៀបជាផ្កាឈើ និងគ្រឿងលាបស្រឡាបជាដើមគ្រប់យ៉ាង ក្នុងព្រះរាជនិវេសន៍ចេញទៅ ឱ្យក្រាលអាសនៈសម្រាប់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានថ្វាយមហាទានចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ក្នុងវេលាសម្រេចភត្តកិច្ច ត្រាស់សួរស្រីនោះថា ព្រះថេរៈរូបណា កាលនាងក្រាបទូលថា រូបនេះ ទ្រង់ជ្រាបហើយថ្វាយបង្គំព្រះសាស្តា ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមភិក្ខុសង្ឃចូរទៅជាមួយនឹងព្រះអង្គ ព្រះថេរៈរូបឯណោះ របស់ខ្ញុំព្រះអង្គនឹងធ្វើអនុមោទនា ។ ព្រះសាស្តាឃាត់ភិក្ខុនោះទុក ហើយស្តេចទៅកាន់

វិហារ ។ ល្មមព្រះថេរៈផ្តើមពោលអនុមោទនា ពេញទាំងព្រះរាជនិវេសន៍ដូចជាពេញទៅដោយក្លិនក្រអូប ។ ព្រះរាជាទ្រង់ជ្រះថ្លាថា នាងនិយាយ ពិតតែម្តង ស្អែកឡើង ទើបសួរដល់ហេតុនោះចំពោះព្រះសាស្តា។ ព្រះសាស្តាត្រាស់ប្រាប់ថាក្នុងអតីតកាលភិក្ខុរូបនេះស្តាប់ធម្មកថា បញ្ចេញវាចាសាធុការថា **សាធុ សាធុ** មិនដាច់ បានស្តាប់ដោយគោរព ម្នាលមហាបពិត្រ ភិក្ខុនោះបានអានិសង្សនេះ មានការបញ្ចេញវាចាសាធុការនោះជាមូល ។

ក្នុងវេលាស្តាប់ព្រះសទ្ធម្ម កាលភិក្ខុនោះ ពោលថា **សាធុ សាធុ** ក្លិនក្រអូបកើតពីមាត់ ផ្សាយចេញទៅដូចក្លិនផ្កាឧប្បលដូច្នោះ ។

## ការអនុមោទនាបុណ្យជាការប្រដៅចិត្តមួយផ្នែក

ការអនុមោទនានូវបុណ្យកុសល ដែលអ្នកដទៃបានធ្វើ ឬបានជូន ក៏ជាការប្រដៅចិត្តមួយផ្នែក កុំឱ្យចិត្តរឹងរូសប្រកាន់ទិដ្ឋិមានះលើកកំពស់ខ្លួន តែធ្វើឱ្យចិត្តទន់ភ្លន់ ស្ងប់ស្ងាត់កំចាត់ការប្រកាន់ខ្លួន ឃើញបុណ្យកុសល ជាធំជាងទ្រព្យសម្បត្តិ មាសប្រាក់ក្នុងលោក ប្រដៅទូន្មានចិត្ត ឱ្យស្គាល់តម្លៃនៃសេចក្តីល្អ ចេះជ្រះថ្លាក្នុងបុណ្យកុសលរបស់អ្នកដទៃ ឃើញអ្នកដទៃ មានសេចក្តីល្អផ្សេងៗថា ជាអ្នកមានគុណ គឺមានគុណចំពោះខ្លួនយើងផង ចំពោះអ្នកដទៃច្រើនផង ចំពោះសាសនាផង កាលដែលអ្នកដទៃ

នោះ ជាអ្នកមានសទ្ធា មានសីល មានចាគៈជាដើម ត្រូវទូន្មានចិត្តឱ្យចេះដឹងគុណអ្នកដទៃ កុំបំភ្លេច កុំលុបបំបាត់ចោលនូវគុណ គឺសេចក្ដីល្អរបស់អ្នកដទៃ ព្រោះហេតុនោះ ចិត្តត្រូវតែយល់ដល់អំពើល្អគ្រប់យ៉ាង ដោយមិនប្រកាន់ឫកចើងម៉ើង ឆ្មើងឆ្មៃ មើលងាយ ឬខឹងក្រោធជាមួយ អ្នកដទៃឡើយ មនុស្សល្អម្នាក់ អាចឱ្យការរស់នៅ និងសេចក្ដីសុខដល់អ្នកដទៃច្រើននាក់ណាស់ក្នុងមួយថ្ងៃៗ ដូច្នេះ គួរប្រមូលមនុស្សល្អទាំងនោះ ឱ្យមកជាខ្លួនយើងតែម្នាក់ ដោយការអនុមោទនាជ្រះថ្លា ត្រេកអរនូវអំពើល្អដែលអ្នកដទៃមាន ជួនកាលអំពើល្អនោះ យើងមិនអាចធ្វើបានផង តើគួររឹងរូស ខឹងប្រកែកឈ្លោះ ឬត្រូវប្រដៅចិត្តឲ្យស្លូត ហើយយើងសម្លឹងមើលគុណ គឺសេចក្ដីល្អរបស់អ្នកដទៃហើយឲ្យតម្លៃយ៉ាងថ្លៃពិតៗ រមែងកម្ចាត់នូវចិត្តអាក្រក់របស់យើងមានការមើលងាយអ្នកដទៃ ដោយអាងទ្រព្យសម្បត្តិ វង្សត្រកូលជាដើមទៀតផង ។

បុណ្យបានមកដោយសារជ្រះថ្លា ពេញចិត្តត្រេកអរទទួលអនុមោទនាចំណែកបុណ្យជាមួយគេ ឬដែលគេបានឱ្យ ។ ការជ្រះថ្លា ពេញចិត្ត ត្រេកអរនូវចំណែកបុណ្យនេះ ទោះជាគេមិនបានឱ្យក៏ដោយ គ្រាន់តែយើងលួចជ្រះថ្លាត្រេកអរក្នុងចិត្តតាមគេ ឬសុំចែកពីគេក៏ដោយ ក៏បានបុណ្យអានិសង្សដូចគ្នាដែរ ព្រោះ

ការលួចបុណ្យគេនេះមិនបាបទេ ឯការសុំបុណ្យពីគេទៀតសោត ក៏មិនមែនជារឿងថោកទាបអ្វីដែរ តែបើគេជ្រះថ្លាបានជូនបុណ្យនោះៗដល់យើង ដោយផ្ទាល់វិញនោះ យើងគ្រាន់តែលើកដៃសំពះ ហើយអនុមោទនា ទទួលយកដោយពោលថា សាធុ ! សាធុ ! សាធុ ! បីដង ដោយចិត្តត្រេកអររីករាយប៉ុនហ្នឹង គឺបានបុណ្យផលានិសង្ស ហាក់ដូចជាយើងបានធ្វើដោយផ្ទាល់អ៊ីចឹងដែរ ។ មានអ្នកខ្លះដោយមិនបានយល់ ឱ្យច្បាស់ពីរឿងនេះ ពេលគេជូនកុសលផលបុណ្យ ហាក់ដូចជាមិនសប្បាយចិត្ត គិតខឹងនឹងអ្នកជូននោះថា ម៉េចចាំបាច់ជូនដល់គេ ។ ធ្វើមើលយើងតែយើងហ្នឹងខ្វះលទ្ធភាព មិនអាចធ្វើបុណ្យដោយខ្លួនឯងបានឬ? ត្រឹមតែលើកដៃសំពះ ហើយពោលថា សាធុ ដោយចិត្តរីករាយប៉ុនហ្នឹង វាគ្មានអ្វីខាតបង់ ឬពិបាកធ្វើនោះឡើយ ។

មានអ្នកខ្លះទៀត ពេលគេជូនបុណ្យមក ធ្វើព្រងើយ ឬធ្វើហី មិនដឹង មិនទាំងចេះទទួលអនុមោទនាបុណ្យកុសល ដែលគេខំជូនហ្នឹងផង ។

**ការអនុមោទនាទទួលយកបុណ្យកុសលនេះ** គឺសំខាន់ខ្លាំងណាស់ ពិសេសសម្រាប់ពពួកប្រេត នរក អសុរកាយ បើមិនចេះអនុមោទនា ទទួលយកកុសលផលបុណ្យហ្នឹងទេ គឺមិនអាចរួចផុតពីកំណើតថោកទាប ទុក្ខទោសវេទនាទាំងអស់នោះ ហើយ

បានទៅកើតក្នុងស្ថានសុគតិភព សួគ៌ ទេវលោកបានឡើយ ។

ម៉្លោះហើយបានជាពេលកំពុងរស់នៅ ត្រូវចេះទទួលអនុមោទនា បុណ្យកុសលឱ្យហើយ ក្រែងលោដំណើរមិនទៀងផ្អៀងគតិ ភ្ញាត់ ធ្លាក់ទៅកើតក្នុងកំណើតថោកទាប មិនល្អ មានកំណើត ប្រេត នរក ជាដើមនោះ ពេលកូនចៅ ញាតិមិត្ត ធ្វើបុណ្យឧទ្ទិសជូនទៅ ចេះអនុមោទនាទទួលយក នាំឱ្យបានរួចផុតពីកំណើតទុក្ខទោសទាំងអស់ហ្នឹង បានទៅកើតក្នុងសុគតិភពវិញ តែបើកាលនៅជាមនុស្ស មិនទាំងចេះអនុមោទនាបុណ្យផង ចុះដល់ពេលស្លាប់ទៅ កូនចៅញាតិមិត្រ ឧទ្ទិសបុណ្យជូនទៅ ធ្វើម៉េចអាចទទួលយកនូវបុណ្យនូវកុសលផលបុណ្យនោះបានទៅ?

ធ្ងន់អ្វីគ្រាន់តែលើកដៃសំពះ ហត់អ្វីម្ល៉េះគ្រាន់តែហាមាត់ថាសាធុនោះ?
គ្រាន់តែទទួលបុណ្យពីគេសោះ តើយើងមានទៅអស់អី ?

## សិក្សាគោលធម៌ផ្សេងៗ
## សុខរបស់អ្នកជាមាតាបិតា និងកូនប្រុសស្រី

មាតាបិតាអាចទទួលសុខ អំពីកូនប្រុសស្រីបាននោះ លុះតែបានសង្គ្រោះកូនដោយធម៌ ៥ យ៉ាងគឺ៖

១/ត្រូវហាមឃាត់កូនកុំឲ្យធ្វើអំពើអាក្រក់

២/ត្រូវដឹកនាំកូនឲ្យតាំងនៅក្នុងអំពើសុចរិតទាំង ១០ មានកាយសុចរិតជាដើម

៣/ត្រូវឲ្យកូនប្រុសស្រីសិក្សាវិជ្ជាទាំងតាមផ្លូវលោកនិងផ្លូវធម៌

៤/ពេលកូនប្រុសស្រីធំពេញវ័យហើយ ត្រូវរៀបចំឲ្យមានគូស្រករ

៥/ត្រូវចែកទ្រព្យឲ្យកូនប្រុសស្រីតាមសមគួរ ។

**ម្ចប់ ៥ យ៉ាងគឺះ**

**១/ សុខំ រក្ខស្ស ឆាយាវ** ម្ចប់ព្រៃព្រឹក្សា

**២/ តតោ ញាតិមាតាបិតា** ម្ចប់ម្ដាយឪពុក ញាតិកា

**៣/ តតោ អាចរិយោ** ម្ចប់គ្រូអាចារ្យ

**៤/ រញ្ញោ** ម្ចប់ស្ដេច

**៥/ តតោ ពុទ្ធស្ស អនេកទា** ម្ចប់ព្រះពុទ្ធ(សាសនា) ។

**សង្វេគវត្ថុ ៨ ប្រការ**

ដែលជាវិធីកម្ចាត់បង់នូវសេចក្ដីប្រមាទ គឺះ

**១/ ជាតិ** ការកើត

**២/ ជរា** ការចាស់ជរា

**៣/ ព្យាធិ** ការឈឺ

**៤/ មរណៈ** សេចក្ដីស្លាប់

**៥/ អបាយទុក្ខំ** ទុក្ខក្នុងអបាយ

**៦/ អតីតេ វដ្តមូលកំ ទុក្ខំ** ទុក្ខមានវដ្តជាមូលក្នុងអតីត

**៧/ អនាគតេ វដ្តមូលកំ ទុក្ខំ** ទុក្ខមានវដ្តជាមូលក្នុងអនាគត

**៨/ បច្ចុប្បន្នេ អហារបរិយយេដ្ឋិមូលកំ ទុក្ខំ** ទុក្ខមានការស្វែងរកអាហារក្នុងបច្ចុប្បន្នជាមូល ។

## លក្ខណៈវិវាហៈ ៨ យ៉ាង

**១/ វិវាហៈដោយលក្ខណៈជាព្រាហ្មណ៍** គឺមាតាបិតាលើកកូនស្រីឲ្យដល់ព្រាហ្មណ៍អ្នកចេះវេទ ដោយមិនបានយកតម្លៃថ្លៃខ្លួនរបស់នាងឡើយ

**២/ វិវាហៈដោយលក្ខណៈជាទេវតា** គឺមាតាបិតាលើកូនស្រីឲ្យដល់ព្រាហ្មណ៍អ្នកធ្វើពិធីបូជាយ័ញ្ញ ជាតម្លៃក្នុងការធ្វើពិធីនេះ

**៣/ វិវាហៈដោយលក្ខណៈជាឫសី** គឺមាតាបិតាលើកកូនស្រីឲ្យដល់បុរសដែលបានឲ្យគោ ក្របី ដល់មាតាបិតា ១គូឬ ២ គូ

**៤/ វិវាហៈដោយលក្ខណៈជាបជាបតី** គឺកាលមាតាបិតានៃស្ត្រីលើកបុត្រីឲ្យដល់បុរស ហើយបានឲ្យឱវាទដល់អ្នកទាំងពីរនោះថា ឯងចូររួមគ្នាប្រព្រឹត្តធម៌

**៥/ វិវាហៈដោយលក្ខណៈជាអសូរៈ** គឺកាលបុរសបានឲ្យទ្រព្យដល់ញាតិនៃស្ត្រីនោះរហូតពេញចិត្ត មាតាបិតានៃស្ត្រីលើកបុត្រីឲ្យជាភរិយា

**៦/ វិវាហៈដោយលក្ខណៈជាអំបូរ ឬច្បាំង** គឺបុរសដណ្តើមស្ត្រីបានមកក្នុងការច្បាំងជាមួយអ្នកគ្រប់គ្រងរបស់ស្ត្រីនោះ

**៧/ វិវាហៈដោយលក្ខណៈជាគុណធម៌** គឺកាលស្ត្រី និងបុរសបានគ្នាដោយសេចក្តីពេញចិត្តទាំងពីរនាក់

**៨/ វិវាហៈដោយលក្ខណៈជាបិសាច** គឺបុរសលបលួចស្ត្រីក្នុងវេលាដែលស្ត្រីនោះដេកលក់ ឬស្រវឹង ឬឡប់មិនមានសតិ ។

## វត្ថុដែលមិនដឹងថាឆ្អែត ១៦ យ៉ាង

**១/សាគរោ សព្វសវន្តីហិ ន តប្បតិ** មហាសមុទ្រសាគរមិនឆ្អែតទៅដោយអំណាចទឹកដែលហូរមកអំពីទិសផ្សេងៗ

**២/អគ្គិ ឧបាទានេន ន តប្បតិ** ភ្លើងមិនឆ្អែតទៅដោយឧស

**៣/រាជា អជ្ជេន ន តប្បតិ** ព្រះមហាក្សត្រមិនឆ្អែតទៅដោយរាជសម្បត្តិ

**៤/ពាលោ បាបេន ន តប្បតិ** ជនពាលមិនឆ្អែតទៅដោយអំពើបាប

**៥/ឥត្ថី មេថុនធម្មេន អលង្ការេន វិជាយនេនាតិ ឥមេហិ តីហិ ន តប្បតិ** ស្ត្រីមិនចេះឆ្អែតទៅដោយវត្ថុ ៣ យ៉ាងគឺ មេថុនធម្ម ១ គ្រឿងប្រដាប់កាយ ១ ការប្រសូត្របុត្រ ១

**៦/ព្រាហ្មណោ មន្តេហិ ន តប្បតិ** ព្រាហ្មណ៍មិនចេះឆ្អែតទៅដោយមន្តទាំងឡាយ

**៧/ឈាយី វិហារសមាបត្តិយា ន តប្បតិ** លោកអ្នកមានឈាន មិនឆ្អែតដោយវិហារសមាបត្តិ

**៨/សេខា អបច្ចយេន ន តប្បតិ** សេក្ខបុគ្គលមិនឆ្អែតទៅដោយធម៌ដែលកិលេសមិនបានសន្សំ គឺព្រះនិព្វាន

**៩/អប្បិច្ឆោ ធុតង្គគុណេន ន តប្បតិ** លោកអ្នកប្រាថ្នាតិច មិនឆ្អែតដោយធុតង្គ អង្គគុណគ្រឿងកម្ចាត់បង់កិលេស

**១០/អារទ្ធវីរិយោ វីរិយារម្ភេន ន តប្បតិ** លោកអ្នកប្រារព្ធសេចក្តីព្យាយាម មិនឆ្អែតទៅដោយសេចក្តីព្យាយាម

**១១/ធម្មិកថិកោ សាកច្ឆាយ ន តប្បតិ** ធម្មកថិកមិនឆ្អែតទៅដោយការសម្តែងធម៌

**១២/វិសារទោ បរិសាយ ន តប្បតិ** បុគ្គលដែលក្លាហាន មិនឆ្អែតទៅដោយការនៅកណ្តាលបរិស័ទ

**១៣/សទ្ធោ សង្ឃុបដ្ឋានេន ន តប្បតិ** លោកអ្នកមានសទ្ធា មិនឆ្អែតទៅដោយការទំនុកបម្រុងព្រះសង្ឃ

**១៤/ទាយកោ បរិច្ចាគេន ន តប្បតិ** ទាយកមិនឆ្អែតទៅដោយការបរិច្ចាគទាន

**១៥/បណ្ឌិតោ ធម្មសវនេន ន តប្បតិ** បណ្ឌិតមិនឆ្អែតទៅដោយការស្តាប់ធម៌

**១៦/ចតស្សោ បរិសា តថាគតទស្សានេន ន តប្បតិ** បរិស័ទទាំង ៤ ពួក មិនឆ្អែតទៅដោយការចូលគាល់ព្រះតថាគត ។

## ជីវិត មានឧបមា ៧ យ៉ាងគឺៈ

នៅក្នុង **អរកានុសាសនីសូត្រ** ព្រះត្រៃបិដកលេខ ៤៧ ទំព័រ ២៤៨ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ **អំពីជីវិតមានប្រមាណតិច** ដែលនិយាយទាក់ទងនឹងគ្រូម្នាក់ឈ្មោះ **អរកៈ** ជាអ្នកធ្វើនូវកំពង់ទៅកាន់សុគតិភព ជាអ្នកប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ឯគ្រូនោះមានសាវ័កច្រើនរយ ។ ក្នុងសម័យនោះ ពួកមនុស្សមានអាយុ ៦០០០០ ឆ្នាំ ។ កុមារិកាមានអាយុត្រឹម ៥០០ ឆ្នាំ ទើបល្មមមានប្តី ។ ហើយសម័យនោះដែរ ពួកមនុស្សមានតែអាពាធ ៦ យ៉ាងគឺ រងា ១ ស្អុះ ១ ឃ្លាន ១ ស្រេក ១ ឈឺឧច្ចារៈ ១ ឈឺបស្សាវៈ ១ ។ ហើយគ្រូនោះតែងសម្តែងធម៌ទូន្មានកូនសិស្សរបស់ខ្លួនយ៉ាងនេះថា ៖

**ម្នាលព្រាហ្មណ៍** ជីវិតពួកមនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយសុទ្ធតែស្លាប់ ។

**ម្នាលព្រាហ្មណ៍** ប្រៀបដូចដំណក់ទឹកសន្សើម លើចុងស្មៅ ដល់ព្រះអាទិត្យរះឡើង ក៏ត្រឡប់បាត់វិញឆាប់រហ័ស ជា

របស់មិនឋិតថេរនៅយូរយារបាន យ៉ាងណា ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ប្រៀបដូចដំណក់ទឹកសន្សើម យ៉ាងនោះដែរ ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយសុទ្ធតែស្លាប់ ។

**ម្នាលព្រាហ្មណ៍** ប្រៀបដូចភ្លៀងមានដំណក់ដ៏ថ្លោសធ្លាក់ចុះមក ក្រពេញទឹកក៏ត្រឡប់បាត់ទៅវិញឆាប់ មិនឋិតថេរ នៅយូរយារបាន យ៉ាងណា ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ប្រៀបដូចជាក្រពេញទឹក យ៉ាងនោះដែរ ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយសុទ្ធតែស្លាប់ ។

**ម្នាលព្រាហ្មណ៍** ប្រៀបដូចស្នាមគំនូសដម្បងលើទឹក តែងត្រឡប់បាត់ទៅវិញឆាប់មិនឋិតថេរ នៅយូរយារបាន យ៉ាងណា ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ប្រៀបដូចស្នាមគំនូសដម្បងលើទឹក យ៉ាងនោះដែរ ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយសុទ្ធតែស្លាប់ ។

ម្នាលព្រាហ្មណ៍ ប្រៀបដូចស្ទឹងហូរពីភ្នំ ហូរទៅកាន់ទីឆ្ងាយ មានខ្សែទឹករហ័ស អាចនាំទៅនូវរបស់ដែលគួរនាំទៅបាន គ្មានកំណត់កាល កំណត់វេលា កំណត់យាមឡើយ ព្រោះស្ទឹងនោះចេះតែទៅ ចេះតែប្រព្រឹត្តទៅ ចេះតែហូរទៅបាន យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ប្រៀបដូចជាស្ទឹងហូរពីភ្នំយ៉ាងនោះដែរ ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយ សុទ្ធតែស្លាប់ ។

ម្នាលព្រាហ្មណ៍ ប្រៀបដូចបុរសដែលមានកម្លាំងគ្រលៀវដុំ ទឹកមាត់ដាក់លើចុងអណ្ដាត ហើយស្ដោះចោលទៅដោយងាយបាន ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ប្រៀបដូចជាដុំទឹកមាត់យ៉ាងនោះដែរ ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយសុទ្ធតែស្លាប់ ។

ម្នាលព្រាហ្មណ៍ ប្រៀបដូចដុំសាច់ដែលគេយកទៅដាក់ក្នុងខ្ទះដែកដ៏ក្ដៅអស់មួយថ្ងៃ រមែងខ្ទេច ចម្រុះធាប់ មិនឋិតថេរយូរយារបាន យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួក

មនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ប្រៀបដូចដុំសាច់ យ៉ាងនោះដែរ ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយសុទ្ធតែស្លាប់ ។

**ម្នាលព្រាហ្មណ៍** ប្រៀបដូចមេគោដែលត្រូវសម្លាប់ ដែលគេ នាំទៅកាន់កន្លែងសម្លាប់ ឈានជំហានណាទៅ ឈ្មោះថាខិតទៅ ជិតកន្លែងសម្លាប់ ជិតសេចក្ដីស្លាប់ យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ប្រៀបដូចជាមេគោដែលត្រូវសម្លាប់យ៉ាងនោះដែរ ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយសុទ្ធតែស្លាប់ ។

ម្នាលភិក្ខុទាំងឡាយ គ្រូឈ្មោះអរកៈនោះ អម្បាលពួកមនុស្សមានអាយុវែងយ៉ាងនេះ ឋិតថេរយូរយារយ៉ាងនេះ មានអាពាធតិចយ៉ាងនេះ ម្ដេចគង់សម្ដែងធម៌ដល់ពួកសាវ័កយ៉ាងនេះថា **ម្នាលព្រាហ្មណ៍** ជីវិតពួកមនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយសុទ្ធតែស្លាប់ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ បើបុគ្គលនិយាយឲ្យត្រូវ ត្រូវនិយាយថា ជីវិតពួកមនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយសុទ្ធតែស្លាប់ ។

**អំណាចរបស់មច្ចុរាជ ១៧ យ៉ាងគឺៈ**

នៅក្នុង គម្ពីរឃ្លាំងបរិយត្តិ លោកបានសម្តែងអំពីអំណាចរបស់មច្ចុរាជ ដែលនៅក្នុងលោកនេះ មិនមានអំណាចណាមួយអាចប្រៀបផ្ទឹមបានឡើយ គឺ ៖

១-យក្ខ បិសាច ប្រេត ពេលដែលខឹងក្រោធហើយ រមែងចូលទៅស្ថិតនៅក្នុងខ្លួនមនុស្សបាន តែមិនអាចចូលទៅស្ថិតក្នុងខ្លួនរបស់ **មច្ចុរាជ** បានឡើយ ។

២-ពួកមនុស្សអាចធ្វើការបន់ស្រន់ បួងសួងនូវយក្ខបិសាច ឬប្រេត ដែលខឹងក្រោធឲ្យចេញបាន តែមិនអាចបន់ស្រន់ បួងសួងអង្វរក **នូវមច្ចុរាជ** បានឡើយ ។

៣-ព្រះរាជាអាចដាក់អាជ្ញាចំពោះអ្នកប្រព្រឹត្តខុស អ្នកចង់ដណ្តើមយកនូវរាជសម្បត្តិ និងអ្នកដែលបៀតបៀនប្រជាជនតាមសមគួរបាន តែមិនអាចដាក់អាជ្ញាចំពោះ **មច្ចុរាជ** បានឡើយ ។

៤-បុគ្គលដែលប្រព្រឹត្តខុស គិតដណ្តើមយកនូវរាជសម្បត្តិ និងអ្នកដែលបៀតបៀនប្រជាជន អាចមានឱកាសសូមឲ្យព្រះរាជា

អត់ឱនទោសឲ្យបាន តែមិនអាចសុំឲ្យ **មច្ចុរាជ** អត់ឱនទោសឲ្យបានឡើយ ។

៥-**មច្ចុរាជ** មិនមានសេចក្ដីអាល័យ ត្រេកអរថា បុគ្គលនេះជាក្សត្រ បុគ្គលនេះជាព្រាហ្មណ៍ (បុគ្គលនេះជាមាតា បុគ្គលនេះជាបិតា បុគ្គលនេះជាកូន...) ឬជាបុគ្គលមាំមួន មានតេជៈច្រើនឡើយ ។

៦-រាជសីហ៍ ខ្លាដំបង ខ្លារខិន រមែងញាំញី ទំពាស៊ីនូវសត្វសត្វៗ បាន តែមិនអាចញាំញី ទំពាស៊ីនូវ **មច្ចុរាជ** បានឡើយ ។

៧-បុគ្គលអ្នកលេងកលល្បិច កាលប្រើនូវកលល្បិចក្នុងទីលាន(កីឡាជាដើម) រមែងអាចបន្លំភ្នែករបស់មហាជនឲ្យវង្វេងជឿបាន តែមិនអាចបន្លំភ្នែក **មច្ចុរាជ** បានឡើយ ។

៨-អាសិរពិស ដែលមានពិសសាហាវ ពេលខឹងក្រោធពួកមនុស្សហើយ រមែងចិកខាំមនុស្សឲ្យដល់សេចក្ដីស្លាប់បាន តែមិនអាចចិកខាំនូវ **មច្ចុរាជ** បានឡើយ ។

៩-អាសិរពិស ពេលខឹងក្រោធ ចិកខាំនូវបុគ្គលណាហើយ គ្រូពេទ្យ រមែងអាចបន្សាបនូវពិសបាន តែមិនអាចបន្សាបពិសរបស់ **មច្ចុរាជ** បានឡើយ ។

១០-គ្រូពេទ្យដែលមានឈ្មោះល្បីល្បាញ រមែងអាចកម្ចាត់នូវពិសរបស់ស្ដេចនាគបាន តែគ្រូពេទ្យទាំងនោះ ត្រូវស្លាប់ទាំង

អស់ លុះក្នុងអំណាចនៃ **មច្ចុរាជ** ។

១១-ពួកវិជ្ជាធរ កាលរាយវិជ្ជាឈ្មោះមោរៈរមែងបបាំងខ្លួនបាន តែមិនអាចបបាំងខ្លួនកុំឲ្យ **មច្ចុរាជ** ឃើញបានឡើយ ។

១២-បុគ្គលដែលប្រកបដោយកម្លាំងកាយក្តី កម្លាំងចិត្តក្តី និងអាចយកឈ្នះកម្លាំងរបស់ **មច្ចុរាជ** បាននោះគឺមិនមានឡើយ ។

១៣-ព្រះរាជាអាចញ៉ាំញីនូវសេនាប្រកបដោយអង្គ ៤ ដែលគួរឲ្យញញើតបាន ហើយដណ្តើមយកជ័យជម្នះបាន តែមិនអាចយកជ័យជម្នះលើសេនារបស់ **មច្ចុរាជ** បានឡើយ ។

១៤-ព្រះរាជាដែលក្លាហាន រមែងបង្ក្រាបនូវនគររបស់សត្រូវឲ្យចុះចូលបាន តែមិនអាចបង្ក្រាបនូវសេនារបស់ **មច្ចុរាជ** បានឡើយ ។

១៥-ព្រះរាជាអាចលោមព័ទ្ធដោយកម្លាំងពលទាំង ៤ ហើយអាចរួចផុតអំពីក្រញាំដៃរបស់សត្រូវបាន តែមិនអាចរួចផុតអំពីក្រញាំដៃរបស់ **មច្ចុរាជ** បានឡើយ ។

១៦-ដំរីចុះប្រេង អាចជាន់ញាំញីនូវនគរទាំងឡាយ និងអាចសម្លាប់នូវប្រជាជនបាន តែមិនអាចញាំញី សម្លាប់នូវសេនារបស់ **មច្ចុរាជ** បានឡើយ ។

១៧-នាយព្រានធ្នូ ដែលបានហ្វឹកហាត់មកល្អហើយ អាចយិត ធ្នូបានឆ្ងាយ និងបាញ់បានត្រង់ មិនភ្លាត់ តែមិនអាចបាញ់ឲ្យត្រូវ ចំ នូវសេនារបស់ **មច្ចុរាជ** បានឡើយ ។

## បុគ្គលដែលមិនខ្លាចស្លាប់

*នៅក្នុង**សៀវភៅធម្មាវលី** លោកក៏បានសម្តែងទៀត អំពីបុគ្គលដែលមិនខ្លាចស្លាប់* **ព្រោះមានធម៌ ៤ យ៉ាងគឺះ**

*១/ជាបុគ្គលប្រាសចាកចាគៈ(សេចក្តីតម្រេក )ក្នុងកាម*

*២/ ជាបុគ្គលមិនមានសេចក្តីស្រឡាញ់ក្នុងកាយ*

*៣/ជាបុគ្គលបានធ្វើបុណ្យទុកមកច្រើន*

*៤/ជាបុគ្គលអស់សេចក្តីសង្ស័យ គឺបានសម្រេចធម៌ ។*

## សទ្ធាធ្វើឲ្យកើតគុណ ១២ ប្រការគឺះ

*នៅក្នុង **គម្ពីរឃ្លាំងបរិយត្តិភាគ ២** លោកក៏បានសម្តែងអំពី* **សទ្ធាធ្វើឲ្យកើតគុណ ១២ ប្រការគឺះ**

*១-កាលបើមានសទ្ធា រមែងចូលទៅរកអ្នកប្រាជ្ញ*

*២-កាលបើចូលទៅរកហើយ រមែងអង្គុយជិត*

*៣-កាលបើអង្គុយជិតហើយ រមែងផ្ទៀងត្រចៀកចុះ*

*៤-កាលផ្ទៀងត្រចៀកចុះហើយ រមែងស្តាប់ធម៌*

*៥-កាលស្តាប់ហើយ រមែងចាំនូវធម៌នោះ*

*៦-កាលចាំនូវធម៌ហើយ រមែងពិចារណាសេចក្តីនៃធម៌*

*៧-កាលពិចារណាសេចក្តីនៃធម៌ហើយ ក៏រមែងអត់ទ្រាំនូវហេតុការណ៍ផ្សេងៗបាន*

*៨-កាលមានធម៌ហើយ ធ្វើឲ្យកើតឆន្ទៈ*

៩-កាលកើតឆន្ទៈហើយ ធ្វើឲ្យកើតនូវឧស្សាហៈ

១០-កាលកើតឧស្សាហៈហើយ រមែងសាកសួរ

១១-កាលសាកសួរហើយ រមែងតាំងសេចក្ដីព្យាយាម

១២-កាលតាំងសេចក្ដីព្យាយាមហើយ រមែងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដោយបញ្ញាដ៏ប្រពៃ ។

## ជីវិតបុគ្គលមានសទ្ធារមែងទទួលបានអានិសង្ស ៥ យ៉ាង

១-**បឋមំ អនុកម្បន្តិ** បុគ្គលមានសទ្ធា ព្រះមានព្រះភាគតែងអនុគ្រោះមុនគេ

២-**បឋមំ ឧបសំកម្មន្តិ** បុគ្គលមានសទ្ធា ព្រះមានព្រះភាគតែងចូលទៅជិតមុនគេ

៣-**បឋមំ បដិគណ្ហន្តិ** បុគ្គលមានសទ្ធា ព្រះមានព្រះភាគតែងចូលទៅទទួលទានមុនគេ

៤-**បឋមំ ធម្មទេសេនំ** បុគ្គលមានសទ្ធា ព្រះមានព្រះភាគតែងសម្ដែងធម៌ឲ្យស្ដាប់មុនគេ

៥-**សគ្គលោកំ ឧបបជ្ជតិ** បុគ្គលមានសទ្ធា កាលស្លាប់ទៅ រមែងចូលទៅកាន់សុគតិ សួគ៌ ទេវលោក ។

# គុណសម្បត្តិរបស់សីល

**១-សីលវា ហិ ពហូ មិត្តេ** បុគ្គលមានសីលរមែងមានមិត្តច្រើន គឺដោយសារតែមិនមានការបៀតបៀន កាប់សម្លាប់គេ ជាអ្នកឲ្យនូវអភ័យទាន នេះឈ្មោះថា រមែងចងមិត្តទុកបាន ព្រោះជាទីស្រឡាញ់ ជាទីពេញចិត្ត

**២-វណ្ណំ កិត្តឹ បសំសញ្ច** បុគ្គលអ្នកមានសីលរមែងបាននូវគុណផង នូវកិត្តិស័ព្ទផង នូវសេចក្តីសរសើរសព្វៗកាលផងអំពីសប្បុរសទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម

**៣-អាទិ សីលំ បតិដ្ឋានំ** សីលជាខាងដើម ជាទីតាំង និងជាអណ្តូងកើតនៃសេចក្តីល្អ គឺសីលរមែងរារាំងនូវអកុសលធម៌ផ្សេងៗមិនឲ្យកើតឡើងបាន ដោយសារមានរបងការពារគឺ សីល

**៤-បមុខំ សព្វធម្មានំ** សីលជាប្រធាននៃធម៌ទាំងពួង គឺជាប្រធានកើតនៃសេចក្តីល្អ អំពើល្អដែលកើតទៅតាមផ្លូវកាយ វាចា

**៥-វេលា ច សំវរំ សីលំ** សំវរៈសីលជាគ្រឿងរារាំងនូវទុច្ចរិត ធ្វើឲ្យចិត្តរីករាយ ទាំងជាកំពង់ឈានចុះកាន់មហាសមុទ្រ គឺព្រះនិព្វាន

**៦-សីលំ ពលំ អប្បដិមំ** សីលជាកម្លាំងរកអ្វីប្រៀបផ្ទឹមមិនបាន គឺជាថាមពលរបស់កំពូលមេទ័ព ដែលមិនមានអ្នកស្មើរបានក្នុងការញាំញីពួកមារ និងសេនានៃមារ

**៧-សីលំអាវុធមុត្តំ** សីលជាអាវុធដ៏ឧត្តមជាគ្រឿងប្រហារដ៏ប្រសើរបំផុត ក្នុងការកាត់នូវសង្គិលេធម៌ ។

**៨-សីលំ អាភរណំ សេដ្ឋំ** សីលជាគ្រឿងអាភរណៈដ៏ប្រសើរ គឺជាសម្បត្តិដ៏ប្រសើរបំផុតរហូតដល់អស់ជីវិត

**៩-សីលំ កវចមព្ភុតំ** សីលជាគ្រឿងក្រោះយ៉ាងអស្ចារ្យ ព្រោះអាចការពារសត្វមានជីវិត ឲ្យរួចផុតពីសេចក្ដីស្លាប់បាន

**១០-សីលំ សេតុ មហេសក្ខោ** សីលជាស្ពានមានស័ក្តិធំ ព្រោះថា មិនលិចចុះក្នុងកិលេស ព្រោះឈានកន្លងត្រពាំងដ៏ធំ គឺសង្សារ

**១១-សីលំគន្ធោ អនុត្តរោ** សីលជាគ្រឿងក្រអូបដ៏ប្រសើរ គឺក្លិនដ៏សែនក្រអូបនៅក្នុងលោកនេះ ជាក្លិនផ្កាក្ដី ក្លិនអ្វីៗក្ដី ដែលថា ក្រអូបនោះផ្សាយទៅបានតែបណ្ដោយខ្យល់តែប៉ុណ្ណោះ, តែបុគ្គលអ្នកដល់ព្រមដោយក្លិនគឺ សីលនោះ រមែងក្រអូបផ្សាយទៅទាំងបណ្ដោយខ្យល់ទាំងបញ្ច្រាសខ្យល់ ទាំងទិសតូច ទិសធំពោលគឺ ទៅកាន់ទិសទាំង ១០

**១២-សីលំ វិលេបនំ សេដ្ឋំ** សីលជាគ្រឿងលាបដ៏ប្រសើរ គឺគ្រឿងលាបនៅក្នុងលោកនេះមានម្សៅជាដើម លាបបានតែខាងក្រៅប៉ុណ្ណោះ ស្អាតបានតែខាងក្រៅ ឯសីលវិញបុគ្គលណាបានយកមកលាបហើយ ជីវិតរបស់បុគ្គលនោះរូបរាងកាយរបស់

បុគ្គលនោះ រមែងល្អស្អាតទាំងខាងក្រៅ ទាំងខាងក្នុង

**១៣-សីលំ សម្ពលមេវគ្គំ សីលជាកញ្ចប់បាយដ៏ប្រសើរ** គឺកញ្ចប់បាយ ឈ្មោះថា ជាស្បៀង។ ពិតណាស់ បុរសស្ត្រីដែលដើរផ្លូវឆ្ងាយ បើមានកញ្ចប់បាយជាប់នឹងខ្លួន រមែងមិនមានសេចក្ដីលំបាកដោយសេចក្ដីទុក្ខ ព្រោះសេចក្ដីស្រេកឃ្លាននៅក្នុងចន្លោះផ្លូវយ៉ាងណា ជីវិតរបស់បុគ្គលដែលបរិបូណ៌ដោយសីលក៏យ៉ាងនោះដែរ គឺរមែងមិនមានសេចក្ដីលំបាក ក្នុងការធ្វើដំណើរទៅកាន់ផ្លូវកន្តារ ដែលជាផ្លូវប្រកបដោយសេចក្ដីទុក្ខយ៉ាងក្រៃលែង ព្រោះហេតុនោះ សីលទើបឈ្មោះថា ជាស្បៀងដ៏ប្រសើរ

**១៤-សីលំ ចាថេយ្យមុត្តមំ សីលជាស្បៀងដ៏ឧត្តម** គឺម្យ៉ាងទៀត សីលឈ្មោះថា ជាស្បៀងសម្រាប់ធ្វើដំណើរដ៏ប្រសើរ ព្រោះមិនទូទៅដល់ពួកចោរជាដើម និងព្រោះធ្វើឲ្យបានសម្រេចសម្បត្តិដែលបុគ្គលនោះប្រាថ្នាហើយ

**១៥-សីលំ សេដ្ឋោ អតិវាហោ សីលជាវាហនៈដ៏ប្រសើរ** គឺនាំទៅយ៉ាងក្រៃលែង ។ ព្រោះសីលជាធម្មជាតិដែលអ្នកៗ មិនអាចប្រទុស្តរាយបាន ជាគុណជាតិដ៏ប្រសើរ ជាពាហនៈដ៏ប្រសើរបំផុត ព្រោះធ្វើឲ្យបានសម្រេចនូវទីឋានដែលបុគ្គលនោះប្រាថ្នាហើយៗ ។

សីលនេះព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ថា ជាអរិយ-

ទ្រព្យដ៏ប្រសើរ ដែលជាទ្រព្យខាងក្នុង មិនទូទៅដល់ទឹក ភ្លើង និង ពួកចោរជាដើម ។ ទ្រព្យនេះបុគ្គលណាមានហើយ តាក់តែង ជីវិតរបស់បុគ្គលនោះ ឲ្យជួបប្រសព្វតែសេចក្ដីសុខទាំងក្នុងលោក នេះនិងលោកខាងមុខ ប្រសើរជាងមានកូនល្អៗ៤, ១០, ២០ នាក់ ធ្វើជាឯកឧត្តម ធ្វើជាលោកជំទាវជាទៀត ព្រោះកូនល្អមានធម៌ កតញ្ញូ អាចទំនុកបម្រុងមាតាបិតាឲ្យបានសេចក្ដីសុខ តែនៅក្នុង បច្ចុប្បន្នប៉ុណ្ណោះ តែមិនអាចចូលទៅទំនុកបម្រុងមាតាបិតាទៅ ក្នុងបរលោកបានទេ តែសីលវិញទំនុកបម្រុងជីវិតបុគ្គលនោះឲ្យ បានសេចក្ដីសុខ ទាំងក្នុងលោកនេះ និងលោកខាងមុខ ។

**អាវុធដ៏ឆ្នើមបំផុតនៅក្នុងលោកនេះ មាន ៤ គឺះ**

**១-សក្កស្ស វជិរាវុធំ** វជិរាវុធរបស់ព្រះឥន្ទ្រ គឺបើព្រះឥន្ទ្រទ្រង់ ខ្វាល់ ហើយប្រហារ **វជិរាវុធ** ត្រង់កំពូលភ្នំសិនេរុ ភ្នំនឹងដាច់ខ្ចាត់ ខ្ចាយចេញពីគ្នា មានចម្ងាយ ១ សែន ៦៨ ពាន់យោជន៍ (១៦៨០០០) រាបស្មើនឹងផែនដី ។

**២-វេស្សវណស្ស គទាវុធំ** ដំបងដែករបស់ស្ដេចវេស្សវ័ណ គឺបើគ្រវែងចោលទៅហើយ នឹងដាច់ក្បាលពួកយក្ខប្រមាណ ១ ពាន់នាក់ធ្លាក់ចុះមួយរំពេច ហើយត្រឡប់មកដល់ដៃដូចដើមវិញ ។

**៣-យមស្ស នយនាវុធំ** ភ្នែករបស់ព្រះយមរាជ គឺបើព្រះ យមរាជខ្ញាស់ហើយ គ្រាន់តែធ្មៀងព្រះនេត្រក៏ធ្វើឲ្យពួកយក្ខកុម្ភណ

ប្រមាណ ១ ពាន់នាក់ ដល់នូវសេចក្ដីវិនាសមួយរំពេច គួរនាដូច ទងស្មៅដែលឆេះក្នុងអម្បែងខ្ទះក្ដៅដូច្នោះ ។

**៤-អាឡវកស្ស ទុស្សាវុធំ** ឈ្មួតក្បាលរបស់អាឡវកយក្ខ បើអាឡវកយក្ខខឹងក្រោធហើយ បើគ្រវែងឈ្មួតក្បាលទៅលើ អាកាស ធ្វើឲ្យរាំងភ្លៀងអស់ ១២ ឆ្នាំ, បើគ្រវែងទៅលើផែនដី រុក្ខ ជាតិលតាជាតិសព្វសារពើ ស្វិតស្រពោនមិនដុះលូតលាស់ឡើង បានអស់ ១២ ឆ្នាំដែរ បើគ្រវែងទៅក្នុងមហាសមុទ្រ ធ្វើឲ្យរីងទឹក អស់ ប្រៀបដូចជាដំណក់ទឹកដែលរីងក្នុងអម្បែងក្ដៅដូច្នោះ បើ គ្រវែងទៅត្រង់ភ្នំធំៗដូចជាភ្នំសិនេរុ ក៏បែកខ្ទាត់ខ្ទាយ ខ្ទេចខ្ទីអស់។

៚ទោះបីអាវុធទាំង៤ នេះមានអានុភាពយ៉ាងនេះក៏ដោយ ក៏មិនអាចនឹងកាប់ផ្ដារនូវកិលេស តណ្ហាបានដែរ តែអាវុធគឺសីល នេះវិញ អាចកាប់ផ្ដារនូវកិលេស តណ្ហាបាន ។

## អានិសង្សកតញ្ញូកតវេទី

១-បុគ្គលនោះបានឈ្មោះថា ជាសប្បុរស

២-បុគ្គលនោះរមែងបានជាទីលើសរសើររបស់អ្នកប្រាជ្ញ

៣-បុគ្គលនោះរមែងជាអ្នកមានខ្ជឹមធម៌ប្រចាំជីវិត

៤-បុគ្គលនោះទេវតាតែងរក្សា

៥-បុគ្គលនោះរមែងមានសេចក្ដីចម្រើនទៅមុខជានិច្ច

៦-បុគ្គលនោះបានឈ្មោះថា ចម្រើនតាមអ្នកប្រាជ្ញ

៧-បុគ្គលនោះបើបានកូន ក៏បានកូនប្រកបដោយគន្ធធម៌

៨-បុគ្គលនោះជាអ្នកមានទីពឹងដ៏ប្រសើរ

៩-បុគ្គលនោះបានឈ្មោះថា ជាអ្នកមិនប្រមាទ

១០-បុគ្គលនោះរមែងរួចផុតអំពីអន្តរាយផ្សេងៗបាន

១១-បុគ្គលនោះរមែងទទួលបាននូវសម្បត្តិ ៣ គឺមនុស្សសម្បត្តិ ទេវតាសម្បត្តិ និងនិព្វានសម្បត្តិ ។

សម្បត្តិទាំងអស់នេះ បានមកសម្រាប់តែជីវិតរបស់បុគ្គលដែលមាននូវសេចក្ដីកតញ្ញូកតវេទីប៉ុណ្ណោះ ។

## អានិសង្សរបស់បុគ្គលដែលប្រព្រឹត្តធម៌ ១០ យ៉ាងគឺ:

១-ជាមហាកុសលដ៏ធំធេង ព្រោះការមាននូវធម៌

២-ជាអ្នកមានឈ្មោះថាមិនប្រមាទនៅក្នុងជីវិត គឺការសាងនូវសេចក្ដីល្អ ដែលជាមាគ៌ាឆ្ពោះទៅកាន់សេចក្ដីសុខ

៣-បានឈ្មោះថា ជាអ្នករក្សានូវព្រះសទ្ធម្មរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ឲ្យគង់វង្ស ឋិតថេរបាន

៤-ជាបុគ្គលចូលរួមផ្សព្វផ្សាយព្រះពុទ្ធសាសនាឲ្យរីកចំរើន

៥-រមែងទទួលបាននូវសេចក្ដីសុខទាំងក្នុងលោកនេះ និងលោកខាងមុខ ព្រោះអំពើល្អរបស់ខ្លួន

៦-រមែងរួចផុតអំពីភយន្តរាយផ្សេងៗ ដោយអំពើល្អ

៧-ឈ្មោះថា ជាបុគ្គលឲ្យនូវអភ័យដល់សត្វទាំងឡាយ គឺធ្វើមិនឲ្យសព្វសត្វទាំងឡាយ មានការភ័យខ្លាចដោយអំពើរបស់ខ្លួន

៨-ឈ្មោះថា ដើរតាមមាគ៌ាដែលជាបដិបទារបស់សប្បុរសទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម

៩-រមែងឃ្លាតឆ្ងាយអំពីសត្រូវខាងក្រៅ គឺមនុស្សសត្វទាំងឡាយ និងសត្រូវខាងក្នុង បានដល់កិលេស តណ្ហា អកុសលគ្រប់សព្វបែបប្រការ

១០-ជាបុគ្គលបានសាងនូវសម្បត្តិ ៣ គឺ សម្បត្តិមនុស្ស ទេវតាសម្បត្តិ និងសម្បត្តិដ៏ថ្លៃថ្លា គឺនិព្វាន ។

## ផ្លូវមកនៃសំណាង ៦ យ៉ាង

១/ **សក្កតា** ជាមនុស្សអង់អាច ក្លាហានក្នុងតួនាទីការងារ មិនរុញរាចំពោះអន្តរាយ និងឧបសគ្គ

២/ **ឧជុតា** ជាមនុស្សស្មោះត្រង់ចំពោះតួនាទីការងារមិនបណ្តោយឲ្យពេលវេលាកន្លងទៅ និងចេះបំពេញកិច្ចការរបស់ខ្លួន និងអ្នកដទៃ

៣/ **សុហុជុតា** ជាមនុស្សស្មោះត្រង់ មិនមានមាយា ហើយបានទទួលការទុកចិត្តពីអ្នកធំ

៤/ **សោវចស្សតា** ជាមនុស្សងាយប្រដៅ មិនរឹងត្អឹង

៥/ **មុទុតា** ជាមនុស្សមានអធ្យាស្រ័យទន់ភ្លន់ គួរឲ្យស្រឡាញ់

៦/ **អនតិមានិតា** ជាមនុស្សមិនក្រអឺតក្រអាង មិនលើកខ្លួនទៅប្រៀបផ្ទឹមនឹងអ្នកដទៃ ។

## ផ្លូវមកនៃប្រយោជន៍ ៦ យ៉ាង

**១/អារោគ្យំ** សេចក្តីមិនមានរោគជាលាភដ៏ប្រសើរ ប្រមើល៍មើលលោកដោយខ្សែភ្នែកដ៏ជ្រះថ្លា អាចញ៉ាំងភោគដែលនៅមិនទាន់កើតឲ្យកើតឡើងបាន រាងកាយសប្បាយ ចិត្តជ្រះថ្លា ឃើញលោកនេះ និងលោកខាងមុខដូចជារបស់ខ្លួនអីចឹង

**២/សីលំ** សេចក្តីប្រព្រឹត្តល្អតាមផ្លូវកាយ វាចា ចិត្ត អានិសង្សសីលមាន ៥ ប្រការ

**៣/ពុទ្ធានុមតិ** ប្រព្រឹត្តតាមអ្នកចេះដឹង រមែងបរិបូណ៌ដោយការចេះដឹង

**៤/សុតំ** ការស្តាប់ដែលជាសមុដ្ឋាននាំឲ្យកើតបញ្ញា ហើយនិងបាននូវប្រយោជន៍ក្នុងលោកនេះយ៉ាងពិត

**៥/ធម្មានុវត្តិ** ការប្រព្រឹត្តតាមធម៌ រមែងមានតែសុចរិត

**៦/អលីនតា** សេចក្តីមិនមានចិត្តតក់ស្លុតរមែងមានតែការរីកចំរើនជានិច្ច ។

## បុគ្គលដែលអាចរលឹកជាតិបាន ៦ ជំពូក

១/ តិរត្ថី រលឹកជាតិបាន ៤ កប្ប

២/ បកតិសាវ័ក រលឹកបាន១០០ ដល់ ១០០០ កប្ប

៣/ អសីតិមហាសាវក(៨០ អង្គ) បាន១ សែនកប្ប

៤/ ព្រះអគ្គសាវ័កឆ្វេងស្តាំបាន ១ អសង្ខេយ្យ ១សែនកប្ប

៥/ ព្រះបច្ចេកពុទ្ធបាន ២ អសង្ខេយ្យ និង ១ សែនកប្ប

៦/ ព្រះពុទ្ធអាចរលឹកបានមិនមានកំណត់ ។

**បុគ្គលដែលមិនបានជួបព្រះសិរអារ្យមេត្រី ៦ ជំពូក**

១/ បុគ្គលអ្នកធ្វើអនន្តរិយកម្ម (៥)

២/ បុគ្គលជានិយតមិច្ឆាទិដ្ឋិ

៣/ បុគ្គលអ្នកមិនសទ្ធាជ្រះថ្លាក្នុងព្រះរតនត្រ័យ

៤/ បុគ្គលដែលមានបុណ្យវាសនាតិច

៥/ ពួកតិរត្ថី និគ្រន្ថ

៦/ បុគ្គលដែលលួចរបស់សង្ឃ ។

**សម្បត្តិរកបានដោយក្រម ៦ យ៉ាង**

១/ **គតិសម្បត្តិ** ការបានអត្តភាពជាមនុស្ស

២/**កាលសម្បត្តិ** ការបានកើតមកក្នុងពេលដែលមានពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ

៣/ **បទេសសម្បត្តិ** ការបានរស់នៅក្នុងប្រទេសដែលមានព្រះពុទ្ធសាសនា

៤/ **កុលសម្បត្តិ** ការបានរស់នៅក្នុងត្រកូល ឬតំបន់ដែលជាអ្នកជ្រះថ្លាក្នុងព្រះពុទ្ធសាសនា

៥/ **ឧបធិសម្បត្តិ** ការបានអត្តភាពពេញបរិបូណ៌ មិនវិកលវិការ គរ ខ្វាក់ ថង់ ផងឹតភ្នែកជាដើម

៦/ **ទិដ្ឋិសម្បត្តិ** ជាអ្នកមានការឃើញត្រូវជាសម្មាទិដ្ឋិ ។

បើយើងបានទូវសម្បត្តិទាំងអស់នេះហើយ គួរកុំឲ្យឱកាសនេះកន្លងហួសឡើយ ព្រោះសម្បត្តិទាំងនេះរកបានលំបាកណាស់ ។

## កំណាត់ទ្រព្យ ៤ យ៉ាង

១/ **ថាវនិធិ** កំណាត់ទ្រព្យដែលមិនអាចឃ្លាកចាកទីបាន មាន ស្រែក ចំការជាដើម

២/ **ជង្គមនិធិ** កំណាត់ទ្រព្យឋិតនៅលើដី មានសេះ ដំរី ប្រុស ស្រីជាដើម

៣/ **អង្គសមនិធិ** កំណាត់ទ្រព្យក្នុងខ្លួនគឺវិជ្ជា

៤/ **អនុគាមិកនិធិ** កំណាត់ទ្រព្យជាប់តាមខ្លួន គឺបុណ្យកុសល ។

## ឧឡារិធម៌ គឺធម៌ជាគ្រឿងចម្រើន ៥ យ៉ាង

១/ **សទ្ធា** សេចក្តីជឿនូវការត្រាស់ដឹងរបស់ព្រះពុទ្ធ

២/ **សីល** ការរក្សាកាយ វាចា ចិត្តឲ្យមានរបៀបរៀបរយ

៣/ **សុតៈ** ការបានស្តាប់ បានរៀនមកច្រើន

៤/ **ចាគៈ** ការលះបង់នូវវត្ថុខាងក្រៅ និងខាងក្នុង

៥/ **បញ្ញា** សេចក្តីដឹង ។

## ចូរពិចារណាអត្តភាពឲ្យមានលក្ខណៈ ៤ យ៉ាង

១/ **ចិត្តកតំ** ដែលកម្មកាត់តែងឲ្យវិចិត្រល្អស្អាត ដោយអាកណៈផ្សេងៗ

២/ **អរុកាយំ** កាយនេះជាដំបៅដោយមានមាត់ដំបៅទាំង ៩ (កន្លែងហូរចេញជានិច្ច)

៣/ **អាតុរំ** មានជម្ងឺជានិច្ច

៤/ **នត្ថិ ធុវំ** មិនមានសេចក្តីមាំមួនឋិតថេរទេ ។

**ជីវិត គឺអត្តភាពមានលក្ខណៈ ៤ នេះ មានសេចក្តីស្លាប់ជាទីបំផុត**

១/ **បរិជិណ្ណមិទំ រូបំ** រូបនេះគ្រាំគ្រាហើយ ព្រោះជរា

២/ **រោគនិទ្ធំ** ជាទីសំណាក់អាស្រ័យនៃរោគ

៣/ **បភង្គុណំ** ជារបស់ពុកផុយ

៤/ **បូតិ**កាយនេះជារបស់ស្អុយ គឺថានឹងមានការបែកធ្លាយទៅវិញ មិនអាចឋិតថេរនៅយូរបានទេ ។

## ពុទ្ធភាសិត ៤ ខគឺ

១/**សព្វេ តសន្តិ ទណ្ឌស្ស** សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតចំពោះអាជ្ញា (គឺសេចក្តីស្លាប់)

២/ **សព្វេ ភាយន្តិ មច្ចុនោ** សត្វទាំងឡាយ តែងខ្លាចចំពោះសេចក្តីស្លាប់

៣/ **អត្តានំ ឧបមំ កត្វា** បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមា

៤/ **ន ហនេយ្យ ន ឃាតយេ** មិនគួរសម្លាប់ដោយខ្លួនឯង និងប្រើគេឲ្យសម្លាប់ទេ ។

## សេចក្តីត្រាំត្រា ៤ យ៉ាងគឺ

១/ **ជីរន្តិ វេ រាជរថា សុចិត្តា** រាជរថទាំងឡាយដ៏វិចិត្រល្អ រមែងចាស់

២/ **អថោ សរីរម្បិ ជរំ ឧបេតិ** សូម្បីសរីរៈក៏ដល់នូវសេចក្តីត្រាំត្រាដូចគ្នា

៣/ **សតញ្ច ធម្មោ ន ជរំ ឧបេតិ** តែធម៌របស់សប្បុរសទាំងឡាយ មិនចូលដល់សេចក្តីចាស់ជរា

៤/ **សន្តោ ហវេ សព្ភិ បវេទយន្តិ** សប្បុរសទាំងឡាយ តែងនិយាយឲ្យពួកសប្បុរសផងគ្នាដឹងបាន ។

## ផ្លូវនៃសេចក្តីស្លាប់ និងសេចក្តីមិនស្លាប់

១/ **អប្បមាទោ អមតំ បទំ** សេចក្តីមិនប្រមាទជាផ្លូវមិនស្លាប់

២/ **បមាទោ មច្ចុនោ បទំ** សេចក្តីប្រមាទជាផ្លូវនៃសេចក្តីស្លាប់

៣/ **អប្បមត្តា ន មីយន្តិ** អ្នកមិនប្រមាទរមែងមិនស្លាប់

៤/ **យេ បមត្តា យថា មតា** បុគ្គលដែលប្រមាទប្រៀបដូចជាបុគ្គលដែលស្លាប់ហើយ ។

## វត្ថុដែលជាកំពូលនៃវត្ថុទាំងឡាយ ៤ យ៉ាងគឺៈ

១/ **សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ** សទ្ធាជាទ្រព្យដ៏ប្រសើររបស់មនុស្សក្នុងលោក

២/ **ធម្មោ សុចិណ្ណោ សុខមាវហាតិ** ធម៌ដែលប្រព្រឹត្តល្អ ហើយនាំសេចក្តីសុខមកឲ្យ

៣/ **សច្ចំ ហវេ សាធុរំ រសានំ** បណ្ដាលរសទាំងឡាយ សច្ចៈនេះឯងមានរសឆ្ងាយជាងគេ

៤/ **បញ្ញាជីវឹ ជីវិតមាហុ សេដ្ឋំ** អ្នកប្រាជ្ញទាំងឡាយ តែង ពោលថា អ្នករស់នៅប្រកបដោយបញ្ញា ឈ្មោះថា មានជីវិតដ៏ ប្រសើរ ។

**សុខ ៤ យ៉ាងគឺៈ**

១/ **សុខា យាវ ជរា សីលំ** សីលនាំសេចក្ដីសុខមកឲ្យដរាប ដល់ចាស់ជរា

២/ **សុខា សទ្ធា បតិដ្ឋិតា** សទ្ធាតាំងមាំហើយនាំសុខមកឲ្យ

៣/ **សុខោ បញ្ញាយ បដិលាភោ** ការបានចំពោះនូវបញ្ញានាំ សេចក្ដីសុខមកឲ្យ

៤/ **បាបានំ អករណំ សុខំ** ការមិនធ្វើអំពើអាក្រក់ នាំសេចក្ដី សុខមកឲ្យ

៥/ **បុញ្ញំ សុខំ ជីវិតសង្ខយម្ហិ** បុណ្យនាំសេចក្ដីសុខមកឲ្យ នៅពេលជិតស្លាប់ ។

**សត្វដែលមិនគួរសម្រេចធម៌មាន ១៥ ប្រការ**

១- សត្វតិរច្ឆាន

២ -ប្រេត

៣ -បុគ្គលជាមិច្ឆាទិដ្ឋិ

៤- ក្មេងអាយុទាបជាង ៧ ខួប

៥- បុគ្គលសម្លាប់មាតា

៦- បុគ្គលសម្លាប់បិតា

៧- បុគ្គលសម្លាប់ព្រះអរហន្ត

៨ -បុគ្គលអ្នកបំបែកសង្ឃ

៩- បុគ្គលអ្នកធ្វើលោហិតព្រះពុទ្ធឲ្យពុះពង

១០- បុគ្គលលួចភេទ(ថេយ្យសំវាស)

១១- ភិក្ខុដែលចូលទៅកាន់ពួកតិរ្ថិយ៍

១២ -បុគ្គលដែលប្រទុស្តរាយនាងភិក្ខុនី

១៣- ភិក្ខុដែលត្រូវអាបត្តិសង្ឃាទិសេស ហើយមិនបានធ្វើខ្លួនឲ្យបរិសុទ្ធវិញ

១៤- បណ្ឌក:(ខ្ទើយ)

១៥- ឧភតោព្យញ្ជនក មនុស្សមានភេទពីរ ។

## អនុត្តរិយ:ធម៌ ៦ យ៉ាង

១/ **ទស្សនានុត្តរិយ** ការឃើញដ៏ប្រសើរបំផុត

២/ **សវនានុត្តរិយ** ការស្តាប់ដ៏ប្រសើរបំផុត

៣/ **លាភានុត្តរិយ** ការបានដ៏ប្រសើរបំផុត

៤/ **សិក្ខានុត្តរិយ** ការសិក្សាដ៏ប្រសើរបំផុត

៥/ **បារិចរិយានុត្តរិយ** ការបម្រើដ៏ប្រសើរបំផុត

៦/ **អនុស្សតានុត្តរិយ** ការរឭកដ៏ប្រសើរបំផុត ។

## **វត្ថុដែលប្រព្រឹត្តទៅមិនបាន ១៦ យ៉ាង**

១/ព្រះសម្មាសម្ពុទ្ធកើតឡើងពីរព្រះអង្គក្នុងលោក

២/ស្តេចចក្រពត្តិកើតឡើងពីរអង្គក្នុងលោក

៣/ស្ត្រីមិនអាចជាព្រះពុទ្ធ

៤/ស្ត្រីមិនអាចស្តេចចក្រពត្តិ

៥/ស្ត្រីមិនអាចធ្វើជាព្រះឥន្ទ

៦/ស្ត្រីមិនអាចធ្វើជាមារ

៧/ស្ត្រីមិនអាចធ្វើជាព្រហ្ម

៨/ផលដែលជាទីពេញចិត្តកើតឡើងអំពីកាយទុច្ចរិតមិនមាន

៩/ផលដែលជាទីពេញចិត្តកើតឡើងអំពីវចីទុច្ចរិតមិនមាន

១០/ផលជាទីពេញចិត្តកើតឡើងអំពីមនោទុច្ចរិតមិនមាន

១១/បុគ្គលអ្នកប្រកបដោយកាយទុច្ចរិតទៅកើតក្នុងសុគតិសួគ៌ ទេវលោកមិនបាន

១២/បុគ្គលអ្នកប្រកបដោយវចីទុច្ចរិត ទៅកើតក្នុងសុគតិសួគ៌ ទេវលោកមិនបាន

១៣/បុគ្គលអ្នកប្រកបដោយមនោទុច្ចរិត ទៅកើតក្នុងសុគតិសួគ៌ ទេវលោកមិនបាន

១៤/បុគ្គលអ្នកប្រកបដោយកាយសុចរិត ទៅកើតក្នុងទុគ្គតិវិនិបាត នរកមិនបាន

១៥/បុគ្គលអ្នកប្រកបដោយវចីសុចរិត ទៅកើតក្នុងទុគ្គតិ វិនិបាត នរកមិនបាន

១៦/បុគ្គលអ្នកប្រកបដោយមនោសុចរិត ទៅកើតក្នុងទុគ្គតិ វិនិបាត នរកមិនបាន ។

**អត្ថនៃពាក្យថា មនុស្ស ៣ យ៉ាង**

**១/ មនោ ឧស្សោ ឧសន្តោ អស្សាតិ មនុស្សោ** ជនអ្នកមានចិត្តខ្ពស់ ឈ្មោះថា មនុស្ស

**២/ ហិតាហិតំ មនតិ ជានាតិ វា មនុស្សោ** (សត្តវិសេសោ) សត្វដែលដឹងហេតុដែលជាប្រយោជន៍ និងមិនមែនជាប្រយោជន៍ ឈ្មោះថា មនុស្ស

**៣/ មនុនោ អបច្ចន្តិ វា មនុស្សោ** ជនអ្នកកើតក្នុងពួកនៃមនុស្ស ឈ្មោះថា មនុស្ស ។

**ទ្រព្យសម្បត្តិដែលបានមកត្រូវប្រើប្រាស់ដោយស្ថាន ៥ យ៉ាង**

១/ ចិញ្ចឹមខ្លួននិងមាតាបុត្តភរិយាឲ្យសុខ

២/ ចិញ្ចឹមមិត្តសម្លាប់ឲ្យសុខ

៣/ បំបាត់អន្តរាយដែលកើតអំពីហេតុផ្សេងៗ

៤/ ធ្វើពលី ៥ យ៉ាងគឺ:

ការជួយសង្គ្រោះញាតិ ហៅថា ញាតិពលី

ការទទួលភ្ញៀវដោយគោរព ហៅ អតិពលី

ការធ្វើបុណ្យឧទ្ទិសឲ្យអ្នកស្លាប់ ហៅថា បុព្វបេ្បតពលី

ការបូជាជាសួយសារអាករដល់រដ្ឋ មានបង់ពន្ធដារជាដើម យ៉ាងហៅថា រដ្ឋពលី

ការធ្វើបុណ្យឧទ្ទិសដល់ទេវតាដែលរក្សាផ្ទះ សម្បែង ហៅថា ទេវតាពលី

៥/ បរិច្ចាគទានដល់សមណព្រាហ្មណ៍ អ្នកប្រព្រឹត្តល្អ ។

**ធម្មុទ្ទេស ៤ យ៉ាងគឺៈ**

១/ **ឧបនីយតិ លោកោ អទ្ធុវោ** សត្វលោកមិនទៀង តែងត្រូវជរាំនាំចូលទៅរកមរណៈ

២/ **អតាណោ លោកោ អនភិស្សរោ** សត្វលោកមិនមានគ្រឿងការពារ មិនមានទីពឹងឡើយ

៣/ **អស្សកោ លោកោ សព្វំ បហាយ គមនីយំ** សត្វលោកសុទ្ធតែមិនមានអ្វីជារបស់ខ្លួន ត្រូវតែលះបង់របស់ទាំងពួង

៤/ **ឩនោ លោកោ អតិត្តោ តណ្ហាទាសោ** សត្វលោកមានតែសេចក្ដីខ្វះខាត សុទ្ធតែជាខ្ញុំរបស់តណ្ហា ។

**ជីវិតមានឧបមាដោយធម៌ ៣ គឺ ៖**

**១/ឧបនីយតិ ជីវិតមប្បមាយុំ** ជីវិត គឺអាយុមានប្រមាណតិច ដ្បិតជរាតែងនាំចូលទៅរកមរណៈ ។

**២/ជរូបនីតស្ស ន សន្តិ តាណា** កាលបើបុគ្គលត្រូវជរានាំចូលទៅរកមរណៈហើយ រមែងមិនមានវិធីការពារឡើយ ។

**៣/ឯតំ ភយំ មរណេ បេក្ខមានោ** បុគ្គលកាលបើសម្លឹងឃើញភ័យក្នុងសេចក្ដីស្លាប់នេះហើយ គួរតែខិតខំធ្វើបុណ្យទាំងឡាយ ដែលជាគុណជាតិនាំសេចក្ដីសុខមកឲ្យ ។

## ធម្មជាតិ ៣ យ៉ាងគឺ:

**១/ អច្ចយន្តិ អហោរត្តា** ថ្ងៃនិងយប់តែងកន្លងទៅ

**២/ ជីវិតំ ឧបរុជ្ឈតិ** ជីវិតតែងរុញថយចុះមក

**៣/ អាយុ ខីយតិ មច្ចានំ** អាយុរបស់សត្វទាំងឡាយ រមែងអស់ទៅ(ដូចទឹកស្ទឹងតូចទាំងឡាយ) ។

## អច្ចេន្តិធម៌

គឺធម៌ជាគ្រឿងកន្លង ៣ យ៉ាងគឺ:

**១/ អច្ចេន្តិ កាលា** កាលទាំងឡាយតែងកន្លងទៅ

**២/ តរយន្តិ រត្តិយោ** រាត្រីទាំងឡាយតែងឆ្លងហួសទៅ

**៣/ វយោគុណា អនុបុព្វំ ជហន្តិ** ជំនាន់នៃវ័យទាំងឡាយតែងលះបង់នូវលំដាប់ ។

កាលបើបុគ្គលបានសម្លឹងឃើញភ័យនោះ ក្នុងសេចក្ដីស្លាប់ហើយ គួរតែធ្វើបុណ្យទាំងឡាយ ដែលជាគុណជាតិនាំសេចក្ដីសុខមកឲ្យ ។

## អគារិយធម៌

គឺធម៌របស់អ្នកគ្រប់គ្រងផ្ទះ ៨ យ៉ាងគឺៈ

**១/ ឧដ្ឋាន** ត្រូវមានសេចក្តីព្យាយាមប្រកបកិច្ចការងារ

**២/ អប្បមត្តោ** ត្រូវជាអ្នកមិនប្រមាទក្នុងការងារ

**៣/ វិធានវា** ត្រូវចេះចាត់ចែងការងារឲ្យបានល្អ

**៤/ សមំ កប្បេតិ ជីវិតំ** ត្រូវជាអ្នកចិញ្ចឹមជីវិតត្រូវ

**៥/ សម្ភតំ អនុរក្ខតិ** ត្រូវចេះថែរក្សាទ្រព្យដែលរកបានមកឲ្យបានគង់វង្ស

**៦/ សទ្ធោ** ត្រូវតែជាអ្នកមានសទ្ធា

**៧/ សីលេន សម្បន្នោ** ត្រូវតែជាអ្នកមានសីល

**៨/ វទញ្ញូ វិតមច្ឆរោ** ត្រូវតែជាអ្នកមានសំដីពីរោះ និងជាអ្នកប្រាសចាកសេចក្តីកំណាញ់ ។

## ហេតុអស្ចារ្យមហាសមុទ្រ ៨ យ៉ាង

ម្នាលភិក្ខុទាំងឡាយ ក្នុងមហាសមុទ្រមានធម្មតាមិនដែលកើតឡើង គួរអស្ចារ្យ ៨ យ៉ាងនេះ ដែលពួកអសុរឃើញហើយតែងរីករាយក្នុងមហាសមុទ្រ ។

១-មហាសមុទ្រមានទំនាបដោយលំដាប់ មានទីជម្រាលដោយលំដាប់ មានទីទេរទៅដោយលំដាប់ មិនមែនចោទជ្រៅទៅតែម្តងដូចជាអណ្តូងទេ ។

២-មហាសមុទ្រមានទឹកតាំងនៅជាធម្មតា មិនដែលឡើង ឬជោរហួសច្រាំងទៅបានទេ ។

៣-មហាសមុទ្រ មិនដែលមានសាកសពស្ងាប់នៅរួមបានទេ បើសាកសពស្ងាប់ ណាមានក្នុងមហាសមុទ្រ រលក់តែងបន្សាត់សាក សពស្ងាប់នោះទៅរកច្រាំង ផាត់ឡើងទៅលើកគោកមួយរំពេច ។

៤-ទន្លេធំៗទាំងឡាយណានីមួយនោះ កាលបើហូរដល់មហាសមុទ្រហើយ តែងលះបង់នាមនិងគោត្រដើមរបស់ខ្លួន ហើយដល់នូវកិរិយារាប់បញ្ចូលថា មហាសមុទ្រតែម្យ៉ាង ។

៥-ទឹកទន្លេទាំងឡាយណានីមួយក្នុងលោក ដែលហូរស្រោចទៅរកមហាសមុទ្រក្តី ទឹកភ្លៀងទាំងឡាយណា ដែលហូរធ្លាក់ចុះមកពីអាកាសក្តី មហាសមុទ្រក៏មិនប្រាកដជាស្រក ឬពេញដោយទឹកទន្លេ និងទ.ទឹកភ្លៀងនោះឡើយ ។

៦-មហាសមុទ្រមានរសតែមួយ គឺរសប្រៃ ។

៧-មហាសមុទ្រមានរតនៈ (ទ្រព្យជាគ្រឿងពេញចិត្ត) ច្រើនយ៉ាង មិនមែនមានតែរតនៈម្យ៉ាងទេ ឯរតនៈទាំងនេះដែលមានក្នុងមហាសមុទ្រនោះ គឺកែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវប្រពាឡ ប្រាក់ មាស កែវក្រហម (ត្បូងទទឹម) និងកែវមរកត ។

៨-មហាសមុទ្រជាទីនៅអាស្រ័យនៃពួកសត្វធំៗ ជាច្រើន

ពួកសត្វធំៗទាំងនេះ (តែងនៅ)ក្នុងមហាសមុទ្រនោះ គឺត្រីឈ្មោះតិមិ ឈ្មោះតិមិង្គល ឈ្មោះតិមិតិមិង្គល ឈ្មោះមហាតិមិង្គល និងពួកអសុរ នាគ គន្ធព្វ ដែលមានអត្តភាព ១០០ យោជន៍ខ្លះ មានអត្តភាព ២០០ យោជន៍ខ្លះ មានអត្តភាព ៣០០ យោជន៍ខ្លះ មានអត្តភាព ៤០០ យោជន៍ខ្លះ មានអត្តភាព ៥០០ យោជន៍ខ្លះ តែងនៅក្នុងមហាសមុទ្រ ។

## ធម៌គួរឲ្យសង្វេគខ្លាច មិនប្រមាទ

## ពួកនិរយបាល ធ្វើកម្មករណ៍ឈ្មោះ បញ្ចវិធពន្ធន៍ (ចំណង ៥ ប្រការ)នៅក្នុងនរក

១-ពួកនិរយបាលចាប់ផ្តេក(សត្វនរកនោះ)ហើយ បោះដែកគោលដ៏ក្តៅត្រង់ដៃ(ខាងស្តាំ)។

២-បោះដែកគោលដ៏ក្តៅ ត្រង់ដៃខាងឆ្វេង ។

៣-បោះដែកគោលដ៏ក្តៅ ត្រង់ជើង(ខាងស្តាំ) ។

៤-បោះដែកគោលដ៏ក្តៅ ត្រង់ជើងខាងឆ្វេង ។

៥-បោះដែកគោលដ៏ក្តៅចំកណ្តាលទ្រូង ។

សត្វនោះរងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងទីនោះ បើបាប-កម្មនោះ មិនទាន់អស់ដរាបណា ក៏មិនធ្វើមរណកាលដរាបនោះ ។

ពួកនិរយបាលផ្តេកសត្វនរកនោះរួចហើយ ទើបយកដឹងចាំង ។

ពួកនិរយបាលចាប់សត្វនោះ យកជើងឡើងលើ យកក្បាលចុះក្រោម ហើយចាំងដោយកាំបិតព្រា ។

ពួកនិរយបាលទឹមសត្វនរកនោះនឹងរថ ហើយបរទៅបរមកលើប្រថពីដែលភ្លើងកំពុងឆេះសព្វ ភ្លឺសន្ធោសន្ធៅ ច្រាលឆ្អៅ ។

ពួកនិរយបាលប្រើសត្វនរកនោះឲ្យឡើងភ្នំ ឲ្យចុះអំពីភ្នំរងើកភ្លើងដ៏ធំ ដែលកំពុងឆេះក្តៅសព្វ ភ្លឺសន្ធោសន្ធៅ ច្រាលឆ្អៅ ។

ពួកនិរយបាលចាប់សត្វនរកនោះ យកជើងឡើងលើ យកក្បាលចុះក្រោម ទម្លាក់ទៅក្នុងខ្ទះទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងឆេះក្តៅសព្វ ភ្លឺសន្ធោសន្ធៅ ច្រាលឆ្អៅ ។

## សេចក្តីឧបមាទុក្ខនៅក្នុងនរក

⇨.គ្រានោះឯង ព្រះមានព្រះភាគទ្រង់ចាប់ថ្មតូច ប្រមាណប៉ុនបាតដៃ ហើយត្រាស់សួរពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះថាដូចម្តេច ដុំថ្មប្រមាណប៉ុនបាតដៃដែលតថាគតកំពុងកាន់នេះ និងស្តេចភ្នំហេមពាន្ត តើណាធំជាង។

⇨.ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើនដុំថ្មប្រមាណប៉ុនបាតដៃ ដែលព្រះអង្គកំពុងកាន់នេះ តូចពេកណាស់ ប្រៀបផ្ទឹមនឹងស្តេចភ្នំហេមពាន្តនោះ មិនដល់នូវការរាប់ផង មិនដល់មួយចំណិតផង មិនដល់នូវការប្រៀបធៀបផង ។

⇨. ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះមាន

ឧបមេយ្យដូចម្តេច ដូចបុរសដែលគេចាក់ដោយលំពែង ៣០០ រមែងរងទុក្ខ ទោមនស្សណា ព្រោះលំពែងនោះជាហេតុ ។ ទុក្ខនោះឯងប្រៀបផ្ទឹមនឹងទុក្ខរបស់នរក ក៏មិនដល់នូវការរាប់ផង មិនដល់មួយចំណិតផង មិនដល់នូវការប្រៀបធៀបផង ។

⇨.ព្រះអង្គសម្តែងជាមួយនឹងភិក្ខុទាំងឡាយថា ដូចបុរសដាក់នឹមដែលមានច្បោះ(ប្រហោង)តែមួយទៅក្នុងមហាសមុទ្រ ។ ខ្យល់ពីខាងកើតបន្សាត់នឹមនោះទៅខាងលិច ខ្យល់ពីខាងលិចបន្សាត់នឹមនោះទៅខាងកើត ខ្យល់ពីខាងជើងបន្សាត់នឹមនោះទៅខាងត្បូង ខ្យល់ពីខាងត្បូងបន្សាត់នឹមនោះទៅខាងជើង ។ ក្នុងមហាមុទ្រនោះ មានអណ្តើកខ្វាក់មួយ អណ្តើកនោះអំណើះទៅមួយរយឆ្នាំ ទើបងើបឡើងម្តង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះថាដូចម្តេច អណ្តើកខ្វាក់នោះ តើអាចនឹងប្រកកឲ្យចូលទៅក្នុងនឹមដែលមានច្បោះតែមួយនោះបានឬទេ ។

⇨. ភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន មិនបានទេ បពិត្រព្រះអង្គដ៏ចម្រើន បើក្រែងតែកន្លងកាលទៅម្តងៗ យូរអង្វែងណាស់(ទើបអណ្តើនោះ ប្រកកចូលទៅក្នុងច្បោះនឹមនោះបាន) ។

⇨.ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អណ្តើកខ្វាក់នោះប្រកកឲ្យចូលទៅក្នុងនឹមដែលមានច្បោះតែមួយនោះទុកថា ជាឆាប់ណាស់ផង ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គល

ពាលទៅកើតជាវិនិបាតម្តងហើយ កម្រនឹងបានអត្តភាពមកជាមនុស្សវិញ ជាងអណ្តើកខ្វាក់នោះទៅទៀត ដំណើរនោះ តើព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ក្នុងវិនិបាតនោះ មិនមានការប្រព្រឹត្តធម៌ដ៏ស្មើ មិនមានការធ្វើកុសល មិនមានការធ្វើបុណ្យទេ ម្នាលភិក្ខុទាំងឡាយ មានតែការខាំស៊ីនូវគ្នានឹងគ្នា សម្លាប់គ្នាដែលមានកម្លាំងថយ តែងមាននៅក្នុងវិនិបាតនោះ ។

⇨.បុគ្គលពាលនោះឯង ប្រសិនបើអំណើះកាលយូរអង្វែងទៅម្តង ទើបបានមកកាន់អត្តភាពជាមនុស្សក្នុងកាលជាខាងក្រោយ តែងកើតក្នុងត្រកូលថោកទាបគឺៈ

ត្រកូលចណ្ឌាល ត្រកូលអ្នកនេសាទ ត្រកូលអ្នកត្បាញផែង ត្រកូលអ្នកធ្វើរថ ត្រកូលអ្នកកើបសម្រាម ជាត្រកូលកំសត់ឥតមានបាយទឹកភោជន ប្រព្រឹត្តរស់នៅដោយលំបាក ជាត្រកូលរកបាយស៊ី នឹងសំពត់ស្លៀកបានដោយត្រដាបត្រដួស ។

⇨.ម្នាលភិក្ខុទាំងឡាយ មហានរកនោះសោតៈ

**មានជ្រុងបួន មានទ្វារបួន ចែកចេញជាចំណែកៗ មានរបងដែក ព័ទ្ធជុំវិញ គ្របដោយគម្របដែក ។ ផ្ទៃក្រោមនៃមហានរកនោះសុទ្ធតែដែក មានភ្លើងឆេះភ្លឺប្រាលរន្ទាលផ្សាយទៅបានមួយរយយោជន៍ជុំវិញ តាំងនៅសព្វៗកាល ។**

## សប្បុរសប្រៀបដោយធម៌ ៥ យ៉ាង

១- សប្បុរស ប្រៀបដូចជាទឹកដ៏បរិសុទ្ធ
២- សប្បុរស ប្រៀបដូចជាដើមឈើធំ
៣- សប្បុរស ប្រៀបដូចជាភ្នំថ្មតាន់
៤- សប្បុរស ប្រៀបដូចជាផ្ករលាន់
៥ -សប្បុរស ប្រៀបដូចជាទឹកសមុទ្រប្រៃ ។

## ពិចារណាសេចក្តីស្លាប់មិនមាននិមិត្ត ៥ យ៉ាងគឺៈ

១/ **ជីវិតំ** នឹងស្លាប់នៅអាយុប៉ុន្មានក៏មិនដឹង
២/ **ព្យាធិ** នឹងស្លាប់ដោយជំងឺអ្វីក៏មិនដឹង
៣/ **កាលោ** នឹងស្លាប់នៅវេលាថ្ងៃ ឬយប់ក៏មិនដឹង
៤/ **ទេហនិក្ខេបនំ** នឹងស្លាប់នៅក្នុងស្រុក ឬព្រៃក៏មិនដឹង
៥/ **គតិ** កាលស្លាប់ទៅកើតទីណាក៏មិនដឹង ។

## សមយសូត្រ

**យេ កេចិ ពុទ្ធំ សរណំ គតាសេ**
**ន តេ គមិស្សន្តិ អបាយភូមឹ**
**បហាយ មនុសំ ទេហំ**
**ទេវកាយំ បរិបូរេស្សន្តីតិ ។**

ជនទាំងឡាយណាមួយ បានដល់នូវព្រះពុទ្ធ ជាទីរឭក ជនទាំងនោះនឹងមិនទៅកាន់អបាយភូមិឡើយលុះលះបង់រាងកាយជារបស់មនុស្សហើយ នឹងទៅបំពេញក្នុងពួកនៃទេវតាមិនខាន ។

## មាតុបោសកសូត្រ

យោ មាតរំ បិតរំ វា
មច្ចោ ធម្មេន បោសតិ
តាយ នំ បារិចរិយាយ
មាតាបិតូសុ បណ្ឌិតា ។

បុគ្គលណាចិញ្ចឹមមាតា ឬបិតាដោយធម៌ បណ្ឌិតទាំងឡាយ រមែងសរសើរបុគ្គលនោះ ក្នុងលោកនេះ ព្រោះការបម្រើមាតាបិតាទាំងឡាយនោះ លុះបុគ្គលនោះទៅកាន់បរលោកហើយ រមែងរីករាយក្នុងឋានសួគ៌ ។

## មានត្ថទ្ធសូត្រ

ព្រះអង្គត្រាស់ថា បុគ្គលមិនគួរធ្វើមានះចំពោះមាតាបិតាបង និងអាចារ្យជាគម្រប់ ៤ គួរប្រកបដោយសេចក្ដីចំពោះបុគ្គលទាំង ៤នោះ បុគ្គលទាំង ៤នោះ បុគ្គលគួរលំអុតលំអោន ម្យ៉ាងទៀតបុគ្គលទាំង ៤ នោះ ដែលគួរបូជាល្អហើយ ញុំាងប្រយោជន៍ឲ្យសម្រេច ។

បុគ្គលគួរកម្ចាត់មានះ មិនគួររឹងត្អឹងដោយអនុស័យ គឺមានះនោះចំពោះព្រះអរហន្ត ដែលមានសេចក្ដីត្រជាក់ មានសោឡសកិច្ចធ្វើរួចហើយ មិនមានអាសវៈ ជាអ្នកប្រសើរ ។

## តតិយទេវសូត្រ

*មាតាបេតិករំ ជន្តុំ កុលេ ជេដ្ឋាបចាយិនំ*
*សណ្ហំ សខិលសម្ភាសំ បេសុណេយ្យប្បហាយិនំ*
*មច្ឆេរវិនយេ យុត្តំ សច្ចំ កោធាភិភុំ នរំ*
*តំ វេ ទេវា តាវតឹសា អាហុ សប្បុរិសោ ឥតីតិ ។*

*ព្រះមានព្រះភាគ បានត្រាស់យ៉ាងនេះថា៖*

*ពួកទេវតានៅឋានតាវត្តិង្ស បានហៅជនអ្នកចិញ្ចឹមមាតាបិតា គោរពកោតក្រែងបុគ្គលជាច្បងក្នុងត្រកូល មានវាចាល្អិតល្អន់ទន់ និយាយវាចាផ្អែមល្ហែម លះបង់ពាក្យញុះញង់ ប្រកបតែក្នុងការកម្ចាត់បង់សេចក្តីកំណាញ់ មានវាចាទៀងទាត់ ជាជនគ្របសង្កត់សេចក្តីក្រោធនោះឯងថា ជាសប្បុរស ។*

## សេរីសូត្រ

*ព្រះមានព្រះភាគបានត្រាស់នូវភាសិតនេះថា៖*

*ពួកជនណាមានចិត្តជ្រះថ្លា ឲ្យនូវបាយនោះដោយសទ្ធា បាយនោះឯង រមែងទៅតាមនូវពួកជននោះក្នុងលោកនេះផង ក្នុងលោកខាងមុខផង ព្រោះហេតុនោះ បុគ្គលគប្បីបន្ទោបង់នូវសេចក្តីកំណាញ់ គ្របសង្កត់នូវមន្ទិល គឺសេចក្តីកំណាញ់ ហើយឲ្យនូវទាន (ព្រោះ)បុណ្យទាំងឡាយ រមែងជាទីពឹងរបស់ពួកសត្វក្នុងលោកខាងមុខ ។*

## បឋមអប្បមាទសូត្រ

ព្រះមានព្រះភាគបានត្រាស់នូវភាសិតនេះថា៖

បុគ្គលកាលប្រាថ្នានូវអាយុ ភាពជាអ្នកមិនរោគ សម្បុរ-កាយ ឋានសួគ៌ ត្រកូលខ្ពង់ខ្ពស់ និងសេចក្ដីត្រេកអរទាំងឡាយដ៏លើសលប់តៗទៅ (គួរតែធ្វើសេចក្ដីមិនប្រមាទ) បណ្ឌិតទាំងឡាយតែងសរសើរសេចក្ដីមិនប្រមាទក្នុងបុញ្ញកិរិយាវត្ថុទាំងឡាយ បណ្ឌិតទាំងឡាយ ជាអ្នកមិនប្រមាទ តែងបានប្រយោជន៍ទាំងពីរ គឺប្រយោជន៍ណាក្នុងបច្ចុប្បន្នក្តី ប្រយោជន៍ណាក្នុងបរលោកក្ដី ធីរជនឈ្មោះថា បណ្ឌិត ព្រោះការបាននូវប្រយោជន៍ទាំងពីរនោះ ។

## ឋានសូត្រ

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់អំពីលក្ខណៈរបស់បុគ្គលដែលមាន***សទ្ធា ៣ យ៉ាង***គឺ៖

***១- ទសនកាមោហោតិ*** គឺចង់ឃើញបុគ្គលមានសីល

***២-សទ្ធម្មំសោតុមិច្ឆតិ*** ចង់ស្ដាប់ព្រះសទ្ធម្ម

***៣-វិនេយ្យមច្ឆេរមាសំ*** កម្ចាត់បង់នូវមន្ទិលគឺសេចក្ដីកំណាញ់។

## អយ្យិកាសូត្រ

ព្រះមានព្រះភាគបានត្រាស់នូវភាសិតនេះថា៖

សត្វទាំងឡាយមុខជានឹងស្លាប់ ព្រោះថាជីវិតរបស់សត្វមានសេចក្ដីស្លាប់ជាទីបំផុត សត្វទាំងឡាយទទួលយកផលបុណ្យផលបាបហើយ នឹងទៅតាមយថាកម្ម គឺអ្នកធ្វើបាប តែងទៅកាន់

នរក ចំណែកខាងអ្នកធ្វើបុណ្យ តែងទៅកាន់សុគតិភព ព្រោះហេតុនោះ បុគ្គលគួរតែធ្វើបុណ្យដែលនាំទៅកាន់បរលោកឲ្យចំរើន (ព្រោះថា)បុណ្យទាំងឡាយ ជាទីពឹងរបស់ពួកសត្វក្នុងបរលោក ។

## បត្តានុមោទនាមយៈ ចប់

# គម្ពីរជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះ

-គម្ពីរព្រះត្រៃបិដករបស់ពុទ្ធសាសនបណ្ឌិត ព.ស. ២៥៥៧

-អដ្ឋកថាពន្យល់សេចក្តីនៃគម្ពីរព្រះត្រៃបិដក ព.ស. ២៥២២

-គម្ពីរឃ្លាំងបរិយត្តិភាគ ១-២ ព.ស. ២៥២៧

-សៀវភៅធម្មាវលី របស់ភិក្ខុ ធម្មវរាចារ្យ

-គម្ពីរបរមត្ថជោតិកា បរិច្ឆេទទី ៥ ក្បាលទី ១ ព.ស. ២៥២០

-បុញ្ញកិរិយាវត្ថុ លោកគ្រូ ភួង សុវណ្ណ ព.ស. ២៥៥៥

-វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ព.ស. ២៥១១

-ព្រមទាំងឯកសាមួយចំនួនទៀត

# ព្រះពុទ្ធគាថា

**យថាបិ ចន្ទោ វិមលោ គច្ឆំ អាកាសធាតុយា**
**សព្វេ តារគណេ លោកេ អាភាយ អតិរោចតិ**
**តថេវ សីលសម្បន្នោ សទ្ធោ បុរិសបុគ្គលោ**
**សព្វេ មច្ឆរិនោ លោកេ ចាគេន អតិរោចតិ។**

*ព្រះច័ន្ទមិនមានមន្ទិល កាលចរទៅតាមអាកាស រមែងរុងរឿងលើសជាងពួកផ្កាយទាំងអស់លើអាកាស ដោយពន្លឺរបស់ខ្លួនយ៉ាងណាមិញ បុរសបុគ្គលមានសទ្ធា បរិបូរណ៌ដោយសីល រមែងរុងរឿងជាងពួកបុគ្គលកំណាញ់ទាំងអស់ក្នុងលោកដោយចាគៈក៏យ៉ាងនោះដែរ ។*